ក្រសួងអប់រំ យុវជន និងកីឡា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ការវាយតម្លៃក្នុងដំណើរការសិក្សា
## មុខវិជ្ជាគណិតវិទ្យា នៅបឋមសិក្សា



នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ
ឆ្នាំ ២០១៦

បោះពុម្ពនៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ2016 (បោះពុម្ពលើកទី1)

ឯកសារនេះត្រូវបានចងក្រង និងបោះពុម្ពផ្សាយក្រោមការឧបត្ថម្ភផ្នែកថវិការបស់អគ្គលេខាធិការដ្ឋានសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍ និងជំនួយមនុស្សធម៌(DGD) និងជំនួយផ្នែកបច្ចេកទេសរបស់ការិយាល័យហ្វ្លេមីស៍សម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍ និងជំនួយបច្ចេកទេស (VVOB)។ ខ្លឹមសារនៃការបោះពុម្ពផ្សាយនេះមិនស្ថិតនៅក្រោមការទទួលខុសត្រូវរបស់រដ្ឋាភិបាលហ្វ្លេមីស៍ និងរដ្ឋាភិបាលបែលហ្ស៊ិកឡើយ។

**កំណត់សម្គាល់កម្មសិទ្ធិបញ្ញា**

រាល់ការបោះពុម្ពផ្សាយឯកសារត្រូវបានធ្វើឡើងដោយអនុលោមតាមអជ្ញាបណ្ណៈ

Creative Commons Attribution-NonCommercial-ShareAlike 3.0

លើកលែងតែឯកសារដែលមិនបានរាប់បញ្ចូល និងបញ្ជីរក្សាសិទ្ធិខាងក្រោម។ មានន័យថាអ្នកអាចចែកចាយ ថតចម្លង ប្រែសម្រួល និងយកលំនាំតាមឯកសារនេះក្នុងន័យមិនរកកម្រៃដោយពុំចាំបាច់ស្នើសុំការអនុញ្ញាតជាមុនពីអ្នកបោះពុម្ពផ្សាយឡើយ តែប្រសិនបើអ្នកបង្កើត ឬ កែប្រែថ្មីអ្នកត្រូវតែសុំអាជ្ញាបណ្ណពីម្ចាស់ដើមក្នុងលក្ខខណ្ឌដូចគ្នាដែលបានបញ្ជាក់ខាងលើ។ សម្រាប់ព័ត៌មានបន្ថែមអំពីអាជ្ញាបណ្ណខាងលើ សូមចូលទៅកាន់គេហទំព័រ

http://creativecommons.org/licenses/by-nc-sa/3.0/

**ឯកសារមិនរាប់បញ្ចូល និងរក្សាសិទ្ធិ**

ឯកសារមួយចំនួនក្នុងការបោះពុម្ពផ្សាយនេះមិនស្ថិតក្រោមអាជ្ញាបណ្ណខាងលើឡើយ។ ទាំងនេះគឺជាឯកសាររបស់ភាគីទី៣ដែលត្រូវបានប្រើប្រាស់ដោយត្រឹមត្រូវ និងទទួលបានការអនុញ្ញាត។ អ្នកបោះពុម្ពផ្សាយមិនទទួលខុសត្រូវចំពោះលក្ខខណ្ឌច្បាប់ណាមួយ (រួមបញ្ចូលទាំងការធ្វេសប្រហែស) ចំពោះការបាត់បង់ ឬខូចខាតដែលកើតមានឡើងដោយសារការប្រើប្រាស់ផ្នែកណាមួយនៃឯកសាររបស់ភាគីទី៣ឡើយ។

# បុព្វកថា

ការលើកកម្ពស់គុណភាពបង្រៀន និងរៀនគណិតវិទ្យាគឺជាផ្នែកមួយនៃការពង្រឹងគុណភាពសិក្សារបស់សិស្សដែលក្រសួងអប់រំ យុវជន និងកីឡាកំពុងយកចិត្តទុកដាក់។ ដើម្បីសម្រេចគោលដៅនេះ គ្រូបង្រៀនត្រូវចេះពីយុទ្ធវិធីនៃការបង្រៀន ជាពិសេសវិធីវាយតម្លៃក្នុងដំណើរការសិក្សា ដើម្បីឱ្យដឹងពីកម្រិតសមត្ថភាព គំនិតភាន់ច្រឡំរបស់សិស្ស និងផ្តល់ព័ត៌មានត្រឡប់ ដើម្បីជួយសិស្សឱ្យបានទាន់ពេលវេលា ជាពិសេស សិស្សដែលរៀនយឺត។

ដោយសង្កេតឃើញពីកង្វះខាតឯកសារលើផ្នែកនេះ ក្រសួងអប់រំ យុវជន និងកីឡា និងអង្គការ VVOB បានសហការគ្នាចងក្រងឯកសារការបង្រៀនគណិតវិទ្យាប្រកបដោយប្រសិទ្ធភាពលើប្រធានបទ "ការវាយតម្លៃក្នុងដំណើរការសិក្សា"។ ឯកសារនេះបានបកស្រាយអំពីសារៈសំខាន់នៃការវាយតម្លៃក្នុងដំណើរការសិក្សា និងបង្ហាញពីវិធីបញ្ច្រាបការវាយតម្លៃនេះទៅក្នុងការអនុវត្តជាក់ស្តែង។

ក្រសួងសង្ឃឹមថា លោកគ្រូ អ្នកគ្រូនឹងប្រើប្រាស់ឯកសារនេះឱ្យអស់លទ្ធភាពដោយអនុវត្តវិធីវាយតម្លៃក្នុងដំណើរការសិក្សាឱ្យបានសមស្របតាមឱកាស និងខ្លឹមសារមេរៀន ដើម្បីចូលរួមលើកកម្ពស់គុណភាពនៃការអប់រំគណិតវិទ្យានៅកម្ពុជា។

ក្នុងនាមក្រសួងអប់រំ យុវជន និងកីឡា ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រុមគ្រូបង្គោល ថ្នាក់ជាតិគណិតវិទ្យា និងអ្នកជំនួយការបច្ចេកទេសនៃអង្គការVVOB ដែលបានយកអស់កម្លាំងកាយ ចិត្ត បញ្ញា និងស្មារតីក្នុងការកសាងឯកសារដ៏មានសារប្រយោជន៍នេះ។

រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៦

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិត ហង់ ជួន ណារ៉ុន

# អារម្ភកថា

ការលើកកម្ពស់ការយល់ដឹងគណិតវិទ្យាជាគោលបំណងសំខាន់ក្នុងការអប់រំគណិតវិទ្យា។ ដើម្បីសម្រេចគោលបំណងនេះ គ្រូមិនគ្រាន់តែអនុវត្តសកម្មភាពសិស្សមជ្ឈមណ្ឌលប៉ុណ្ណោះទេ ប៉ុន្តែគាត់ត្រូវប្រើវាឱ្យមានប្រសិទ្ធភាពផងដែរ។ ហេតុនេះគ្រូត្រូវមានចំណេះដឹង ជំនាញគរុកោសល្យ និងមានភាពច្បាស់លាស់លើខ្លឹមសារមេរៀន។ ចំណេះដឹងខាងលើនេះរួមមានធាតុផ្សំសំខាន់ៗដូចជា៖
ទី១គឺការយល់ និងចេះប្រើប្រាស់រូបតំណាងពីមេរៀន ទី២គឺការដឹងពីវិធីដែលសិស្សបកស្រាយរូបតំណាង ទី៣គឺចំណេះដឹងនៃគំនិត និងដំណើរការដែលសិស្សទាល់គំនិតពេលគិតពីគណិតវិទ្យា ទី៤គឺចំណេះដឹងលើវិធីវាស់ស្ទង់ និងវាយតម្លៃ និងទី៥គឺចំណេះដឹងពីធនធានសម្បូរបែបដែលមានភាពងាយស្រួលយកមកប្រើក្នុងថ្នាក់រៀន។

ឯកសារនេះកសាងឡើងសម្រាប់អ្នកពាក់ព័ន្ធនានាប្រើប្រាស់។ គ្រូឧទ្ទេសអាចប្រើប្រាស់វាតាមពីររបៀបគឺ៖ គាត់អាចបញ្ជ្រាបវិធីវាយតម្លៃទៅក្នុងដំណើរការបង្រៀនមេរៀន និងក៏អាចបង្រៀនគរុសិស្សពីការវាយតម្លៃដែលជាផ្នែកមួយនៃមេរៀនស្ដីពីគោលវិធីសិស្សមជ្ឈមណ្ឌល (ឆ្នាំទី1 ឆមាសទី1)។ គរុសិស្សអាចប្រើឯកសារនេះអំឡុងពេលចុះកម្មសិក្សា និងសម្រាប់ការស្រាវជ្រាវ។ លើសពីនេះទៅទៀត គ្រូបង្រៀននៅកម្រិតបឋមសិក្សា ក៏អាចប្រើវាជាឯកសារយោងផងដែរ។

យើងខ្ញុំសង្ឃឹមថាគ្រូឧទ្ទេសនឹងសាកល្បងប្រើវិធីបង្រៀនដែលបានបង្ហាញនៅក្នុងឯកសារនេះ។ យើងខ្ញុំរង់ចាំទទួលមតិរិះគន់ស្ថាបនាពីលោក លោកស្រីដោយក្ដីរីករាយ។ សូមជូនពរឱ្យលោក លោកស្រីរីករាយក្នុងការបង្រៀនមេរៀនគណិតវិទ្យា។

**គណៈកម្មការនិពន្ធ**

## គណៈកម្មការរៀបចំឯកសារ

| | | |
|---|---|---|
| **គណៈកម្មការគ្រប់គ្រង** | | |
| ឯកឧត្តមបណ្ឌិត | ហង់ ជួន ណារ៉ុន | រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា |
| ឯកឧត្តមបណ្ឌិត | ណាត ប៊ុនរឿន | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា |
| **គណៈកម្មការត្រួតពិនិត្យ** | | |
| លោក | លាង សេងហាក់ | ប្រធាននាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ |
| លោក | អេង គឹមលី | ប្រធាននាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា |
| លោក | ចាន់ សុភា | ប្រធាននាយកដ្ឋានបឋមសិក្សា |
| **គណៈកម្មការនិពន្ធ** | | |
| លោក | សម សុភ័ក្តិ | អនុប្រធាននាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ |
| លោក | ប៊ូ សន | ប្រធានការិយាល័យ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា |
| លោក | ហែម សុខល័ក្ខ | មន្ត្រី នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ |
| លោក | គ្រិត ចំរើន | មន្ត្រី នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ |
| លោក | គុយ ច័ន្ទមង្គល | មន្ត្រី នាយកដ្ឋានបឋមសិក្សា |
| លោក | ថោង កុសលឫទ្ធិ | គ្រូឧទ្ទេស សាលាគរុកោសល្យ និងវិក្រឹតការរាជធានីភ្នំពេញ |
| អ្នកស្រី | សេខ សុឃឿន | គ្រូឧទ្ទេស សាលាគរុកោសល្យ និងវិក្រឹតការខេត្តព្រៃវែង |
| លោក | ខែម សារ៉ន | គ្រូឧទ្ទេស សាលាគរុកោសល្យ និងវិក្រឹតការខេត្តតាកែវ |
| លោក | ឆេង វុឌ្ឍី | គ្រូឧទ្ទេស សាលាគរុកោសល្យ និងវិក្រឹតការខេត្តកំពង់ឆ្នាំង |
| អ្នកស្រី | ម៉ម បញ្ញាធារី | គ្រូឧទ្ទេស សាលាគរុកោសល្យ និងវិក្រឹតការខេត្តកណ្តាល |
| លោក | សឹង ហ៊ីណារិទ្ធ | គ្រូឧទ្ទេស សាលាគរុកោសល្យ និងវិក្រឹតការខេត្តកំពង់ចាម |
| **អ្នករៀបរៀង** | | |
| អ្នកស្រី | អ៊ិក សុមនី | អនុប្រធាននាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា |
| លោក | ណុប ស្រួយ | មន្ត្រីអប់រំ |
| **ជំនួយការបច្ចេកទេស** | | |
| អ្នកស្រី | ម៉ៅ សុកល្យាណ | អ្នកសម្របសម្រួលកម្មវិធី VVOB |
| កញ្ញា | Debby Van Paesschen | ទីប្រឹក្សាអប់រំ VVOB |
| លោក | អួន វីរៈ | ទីប្រឹក្សាអប់រំ VVOB |
| លោក | វ៉ាន លៀប | ទីប្រឹក្សាអប់រំ VVOB |
| **អ្នកបកប្រែ និងវាយអត្ថបទ** | | |
| អ្នកស្រី | ហេង គឹមហុង | ជំនួយការកម្មវិធី VVOB |
| លោក | ទូច សុវ៉ាណា | ជំនួយការកម្មវិធី VVOB |

# មាតិកា


**សេចក្ដីផ្ដើម** ........ ១

**ជំពូក១ ៖** សារៈសំខាន់នៃការវាយតម្លៃក្នុងដំណើរការសិក្សា........ ២

**ជំពូក២ ៖ ការវាយតម្លៃដោយមានការចូលរួមទាំងអស់គ្នា** ........ ៣

២.១ ការវាយតម្លៃដោយគ្រូ ........ ៣

២.២ ការវាយតម្លៃដោយខ្លួនឯង ........ ៣

២.៣ ការវាយតម្លៃគ្នាទៅវិញទៅមក ........ ៤

**ជំពូក៣ ៖ ការវាយតម្លៃអំឡុងពេលដំណើរការបង្រៀន និងរៀន** ........ ៥

៣.១ សមត្ថភាពមានស្រាប់ ........ ៥

៣.២ ការបង្រៀន........ ៥

៣.៣ ការអនុវត្ត ........ ៦

**ជំពូក៤ ៖ វិធីវាយតម្លៃ**........ ៧

៤.១ បណ្ដាភ្លើងសញ្ញាចរាចរ ........ ៧

៤.២ ព្យុះគំនិត........ ១១

៤.៣ តុក្កតាគំនិត ........ ១៤

៤.៤ ការពិនិត្យឡើងវិញជាមួយដៃគូ........ ១៧

៤.៥ វិធីស្វែងរកដំណោះស្រាយច្រើនបែប........ ១៩

៤.៦ ល្បែងជេអូផាឌី (Jeopardy)........ ២០

៤.៧ ល្បែងផាហ្សល ( Puzzle ) ........ ២៤

**ជំពូក៥ ៖ ការជួយសិស្ស** ........ ២៩
៥.១ ការប្រមូល និងវិភាគទិន្នន័យ ........ ២៩
៥.២ ព័ត៌មានត្រឡប់ ........ ៣១
៥.៣ ការញែកភាពខុសគ្នា ........ ៣១
ឧបសម្ព័ន្ធ ........ ៣៤
ឯកសារយោង ........ ៣៦

# សេចក្តីផ្តើម

ក្នុងសៀវភៅ **ការវាយតម្លៃក្នុងដំណើរការសិក្សា**នៃមុខវិជ្ជាគណិតវិទ្យានៅបឋមសិក្សា យើងគួរប្រើគោលវិធីសិស្សមជ្ឈមណ្ឌលជាគោល។ ថ្វីបើគ្រូភាគច្រើនស្គាល់ពីវិធីនេះក៏ដោយ ប៉ុន្តែការអនុវត្តគោលវិធីនេះនៅមិនទាន់មានប្រសិទ្ធភាពនៅឡើយទេ។



ការបង្រៀនមេរៀនតាមបែបគោលវិធីសិស្សមជ្ឈមណ្ឌលមានភាពស្មុគស្មាញណាស់ដែលទាមទារឱ្យគ្រូមានភាពវៃឆ្លាត ទន់ភ្លន់ ចេះបត់បែនតាមស្ថានភាពជាក់ស្តែងរបស់សិស្ស។ វាពិតជាមិនគ្រប់គ្រាន់ទេដែលគ្រាន់តែធ្វើឱ្យសិស្សមានសកម្មភាពក្នុងពេលបង្រៀន។ ការប្រើប្រាស់សម្ភារឧបទេសបានច្រើន ក៏មិនអាចធានាថាការបង្រៀននោះគោរពតាមគោលវិធីសិស្សមជ្ឈមណ្ឌលដែរ។ ក្នុងការបង្រៀនមេរៀនបែបគោលវិធីសិស្សមជ្ឈមណ្ឌល គ្រូត្រូវមានការទទួលខុសត្រូវផ្សេងទៀត ជាច្រើនក្នុងការរៀបចំសម្ភារៈ និងវិធីបង្រៀនឱ្យមានប្រសិទ្ធភាព។ គ្រូត្រូវតែក្លាយជាអ្នកសម្របសម្រួលយ៉ាងប៉ិនប្រសប់ ជាជាងការផ្ទេរចំណេះដឹងដោយផ្ទាល់។ ហេតុនេះ គ្រូត្រូវមានចំណេះដឹងទូលំទូលាយ មិនត្រឹមតែមានចំណេះដឹងលើខ្លឹមសារនៃមេរៀនគ្រប់គ្រាន់ប៉ុណ្ណោះទេ គាត់ត្រូវមានចំណេះដឹងជាក់លាក់ដើម្បីបង្រៀនមេរៀនតាមបែបគោលវិធីសិស្ស មជ្ឈមណ្ឌលឱ្យមានប្រសិទ្ធភាពរួមទាំង ចំណេះដឹងលើវិធីវាយតម្លៃការយល់ដឹងរបស់សិស្សក្នុងដំណើរការសិក្សាថែមទៀត។ តាមរយៈការវាយតម្លៃការយល់ដឹងរបស់សិស្ស យើងអាចរកឃើញនូវគំនិតភាន់ច្រឡំរបស់សិស្ស និងលទ្ធភាពរបស់គេក្នុងការដោះស្រាយបញ្ហានោះ។ ទង្វើបែបនេះយើងនឹងសម្រេចបាននូវគោលបំណងចុងក្រោយក្នុងការពង្រឹងការយល់ដឹងរបស់អ្នកសិក្សា។

ដើម្បីធ្វើការវាយតម្លៃឱ្យបានត្រឹមត្រូវ យើងគប្បីយល់ច្បាស់ពីអត្ថន័យនៃការវាយតម្លៃឱ្យបានច្បាស់លាស់។ តើការវាយតម្លៃមានន័យដូចម្តេច? ពាក្យ “វាយតម្លៃ” មានអត្ថន័យច្រើន គេអាចញែកពីភាពខុសគ្នារវាងការវាយតម្លៃក្នុងដំណើរការសិក្សា និងការវាយតម្លៃបញ្ចប់។ ជាញឹកញាប់ ការវាយតម្លៃបញ្ចប់ជាការវាយតម្លៃផ្លូវការដែលធ្វើដោយគ្រូនៅពេលចុងវគ្គសិក្សា ចុងខែ ឆមាស ឬ ដំណាច់ឆ្នាំសិក្សា ប៉ុន្តែការវាយតម្លៃក្នុងដំណើរការសិក្សាគឺធ្វើរហូតជាបន្តបន្ទាប់ និងចូលរួមធ្វើសកម្មភាពគ្នាក្នុងដំណើរការបង្រៀន និងរៀន។ វាជាការវាយតម្លៃបែបផ្លូវការផង និងមិនផ្លូវការផង ហើយធ្វើឡើងក្នុងគោលបំណងផ្តល់ព័ត៌មានត្រឡប់ដើម្បីគាំទ្រ និងជួយសិស្ស (VVOB, 2007)។ ប្រភេទនៃការវាយតម្លៃចុងក្រោយនេះនឹងត្រូវបានលើកយកមកបង្ហាញ ក្នុងឯកសារបំប៉ននេះ។ ជំពូកជាបន្តបន្ទាប់ខាងក្រោមនឹងបង្ហាញឱ្យកាន់តែច្បាស់លាស់ និងស៊ីជម្រៅ បន្ថែមទៀតថា តើវិធីវាយតម្លៃក្នុងដំណើរការសិក្សាប្រើដើម្បីអ្វី? នរណាជាអ្នកប្រើ? ប្រើដោយរបៀបណា និងធ្វើយ៉ាងដូចម្តេច?

## ជំពូក១ ៖ សារៈសំខាន់នៃការវាយតម្លៃក្នុងដំណើរការសិក្សា

គោលដៅចុងក្រោយនៃការបង្រៀនគឺបង្កើនការយល់ដឹងដល់អ្នកសិក្សាទាំងអស់។ ប៉ុន្តែដើម្បីឱ្យសិស្សមានសមត្ថភាពធ្វើបែបនេះ គ្រូត្រូវស្គាល់ពីសមត្ថភាពមានស្រាប់របស់ពួកគេ។ ដូច្នេះការវាយតម្លៃក្នុងដំណើរការសិក្សាមានតួនាទីសំខាន់ណាស់។

ក្នុងការបង្រៀនតាមបែបគោលវិធីសិស្សមជ្ឈមណ្ឌល គឺសិស្សត្រូវចូលរួមយ៉ាងសកម្ម ហើយគ្រូជាអ្នកសម្របសម្រួល និងត្រួតពិនិត្យតាមដានគ្រប់សកម្មភាពរបស់ពួកគេ។ គ្រូមិនគ្រាន់តែអង្គុយនៅនឹងតុរបស់គាត់ទេប៉ុន្តែគាត់ត្រូវដើរមើលសិស្សធ្វើកិច្ចការព្រមទាំងធ្វើការសម្របសម្រួលពួកគេផងដែរ។ គ្រូត្រូវឱ្យសិស្សពន្យល់ពីការគិតនិងវាយតម្លៃការយល់ដឹងរបស់ពួកគេ។

គ្រូប្រើប្រាស់ការវាយតម្លៃក្នុងដំណើរការសិក្សាមានគោលបំណងដូចខាងក្រោម៖

- ត្រួតពិនិត្យតាមដាន និងវាយតម្លៃតម្រូវការក្នុងការរៀនសូត្ររបស់សិស្ស។ ស្វែងរកគំនិតភាន់ច្រឡំរបស់សិស្សពាក់ព័ន្ធនឹងចំណេះដឹងមានស្រាប់របស់គេ ប៉ុន្តែមានលក្ខណៈមិនពេញលេញ ឬមិនទាន់ត្រឹមត្រូវ។ ពេលខ្លះវាហាក់ដូចជាត្រឹមត្រូវ សម្រាប់សិស្សដោយសារវាមានលក្ខណៈ អព្ភន្តរញ្ញាណច្រើន(ដឹងដោយមិនបានគិត និងស្រាវជ្រាវឱ្យបានច្បាស់លាស់) ឬ ដោយសារសិស្សបានស្គាល់វាជាយូរមកហើយ។ គំនិតរបស់សិស្សទាំងនេះដើរតួនាទីសំខាន់ក្នុងលទ្ធផលនៃការសិក្សាចុងក្រោយ។
- បង្កើតផែនការជួយសិស្ស គ្រូត្រូវផ្លាស់ប្តូរយុទ្ធវិធីបង្រៀនដើម្បីរំលេចឱ្យឃើញនូវគំនិតភាន់ច្រឡំ និងផ្លាស់ប្តូរគំនិតរបស់ពួកគេឱ្យទាន់ពេលវេលា។ បើគ្រូគ្រាន់តែប្រាប់សិស្សថាការយល់ឃើញរបស់គេមិនទាន់ត្រឹមត្រូវទេ នោះសិស្សមិនងាយផ្លាស់ប្តូរគំនិតរបស់គេបានឡើយ។
- ឆ្លុះបញ្ចាំងលើប្រសិទ្ធភាពនៃការបង្រៀនដើម្បីជួយគ្រូក្នុងការវាយតម្លៃការងារផ្ទាល់ខ្លួន ដូចជាការប្រើប្រាស់វិធីបង្រៀន ការរៀបចំសកម្មភាព សម្ភារៈបង្រៀន និងអភិវឌ្ឍមេរៀនឱ្យកាន់តែមានប្រសិទ្ធភាពក្នុងពេលអនាគត។

## ជំពូក២ ៖ ការវាយតម្លៃដោយមានការចូលរួមទាំងអស់គ្នា

ជំពូកនេះស្រាយបំភ្លឺពីវិធីដែលអ្នកពាក់ព័ន្ធទាំងអស់ដូចជាគ្រូ សិស្ស និងមិត្តភក្តិរបស់ពួកគេដែលត្រូវបំពេញតួនាទីឱ្យបានត្រឹមត្រូវ។

### ២.១ ការវាយតម្លៃដោយគ្រូ

ការវាយតម្លៃក្នុងដំណើរការសិក្សា គ្រូត្រូវធ្វើការពិនិត្យតាមដានការងារ និងការរីកចម្រើនរបស់សិស្ស រួចហើយកត់ត្រាវាទុក ព្រមទាំងយកចិត្តទុកដាក់ ផ្តល់អនុសាសន៍ និងព័ត៌មានត្រឡប់ ពីសកម្មភាពផ្សេងៗជាច្រើនទៀត ជាជាងការដាក់ពិន្ទុដោយការធ្វើតេស្ត។



ការរក្សាកំណត់ត្រានៃការរីកចម្រើនរបស់សិស្សមានមុខងារបីយ៉ាង៖

- ជាជំនួយក្នុងការផ្តល់ព័ត៌មានត្រឡប់ និងដំបូន្មានមួយចំនួនដល់សិស្សសម្រាប់កែលម្អ
- ជាជំនួយក្នុងការរាយការណ៍ទៅអាណាព្យាបាល គ្រូដទៃទៀត និងអ្នកដែលពាក់ព័ន្ធផ្សេងទៀត
- ជាជំនួយក្នុងការធ្វើផែនការសកម្មភាពបង្រៀន និងរៀនដើម្បីឱ្យសមស្របទៅនឹងកម្រិតយល់ដឹង និងការរីកចម្រើនរបស់សិស្ស។

### ២.២ ការវាយតម្លៃដោយខ្លួនឯង

ការវាយតម្លៃការសិក្សារបស់សិស្ស មិនមែនមានតែគ្រូទេ ប៉ុន្តែសិស្សក៏ត្រូវវាយតម្លៃការសិក្សាដោយខ្លួនឯងផងដែរ។ វិធីនេះជួយលើកទឹកចិត្តឱ្យគេមានការទទួលខុសត្រូវខ្ពស់។

នៅពេលសិស្សធ្វើការងាររបស់គេចប់ គេអាចប្រើអត្រាកំណែ(ចម្លើយ)ដើម្បីផ្ទៀងផ្ទាត់កិច្ចការរបស់គេតាមរយៈចម្លើយដែលគេបានរកឃើញ។ ផ្អែកលើការឆ្លុះបញ្ចាំងនេះ គេអាចកែតម្រូវការងាររបស់គេបាន។ តែបើសិនជាគេមិនអាចដោះស្រាយដោយខ្លួនឯងបាន គេអាចសុំជំនួយពីមិត្តរួមថ្នាក់ ឬគ្រូរបស់ពួកគេ ដើម្បីធ្វើការសម្របសម្រួល។

បន្ទាប់ពីសិស្សធ្វើការវាយតម្លៃដោយខ្លួនឯងរួច គ្រូត្រូវពិភាក្សាជាមួយសិស្សដើម្បីឱ្យដឹងថា តើសិស្សបានរៀនអ្វីខ្លះ? តើសិស្សបានបង្កើតកំហុសអ្វីខ្លះ? តើសិស្សអាចឈានទៅរកចម្លើយត្រឹមត្រូវដោយវិធីណា?

## ២.៣ ការវាយតម្លៃគ្នាទៅវិញទៅមក



ក្រៅពីការប្រើវិធីខាងលើ ដើម្បីវាយតម្លៃសិស្សនៅក្នុងថ្នាក់ គ្រូបង្រៀនអាចប្រើវិធីវាយតម្លៃដោយឱ្យសិស្សធ្វើការវាយតម្លៃកិច្ចការគ្នាទៅវិញទៅមក។ ដើម្បីធានាប្រសិទ្ធភាពនៃការងារនេះ សិស្សត្រូវទទួលការណែនាំនូវបំណិនព្រមទាំងរបៀបនៃការវាយតម្លៃគ្នាទៅវិញទៅមកជាប្រក្រតី។ គ្រូឱ្យសិស្សបង្កើតការងារធ្វើដោយខ្លួនឯង ហើយពេលធ្វើចប់ ត្រូវប្តូរកិច្ចការគ្នាទៅវិញទៅមកជាមួយដៃគូ។ ដៃគូត្រូវគូសរបារពីក្រោមលំហាត់ដែលគេគិតថាមិនត្រឹមត្រូវ។ ដៃគូដទៃទៀតត្រូវបន្តធ្វើរបៀបនេះដូចៗគ្នា។ បន្ទាប់ពីបានកែតម្រូវរួចហើយពួកគេត្រូវធ្វើការពិភាក្សាគ្នា ហើយទាញយកចម្លើយត្រឹមត្រូវមួយដោយមានការយល់ស្របពីមិត្តរួមក្រុម។ គ្រូត្រូវតែដឹកនាំដំណើរការនេះ ដើម្បីឱ្យដឹងច្បាស់ថាតើសិស្សទាំងអស់ពិតជាបានចូលរួមពិភាក្សា និងរៀនពីគ្នាទៅវិញទៅមក។ សិស្សទាំងអស់ត្រូវពន្យល់ និងបកស្រាយនូវចម្លើយរបស់ខ្លួននៅចុងបញ្ចប់នៃសកម្មភាព ចំណែកគ្រូត្រូវផ្តល់ព័ត៌មានកែលម្អជាចុងក្រោយសម្រាប់ការងាររបស់ពួកគេ។

## ជំពូក៣ ៖ ការវាយតម្លៃអំឡុងពេលដំណើរការបង្រៀន និងរៀន

ជំពូកនេះចង្អុលបង្ហាញពីរបៀបវាយតម្លៃក្នុងដំណើរការសិក្សា ដែលអាចបញ្ជ្រាបទៅក្នុងដំណាក់កាលនីមួយៗនៃមេរៀន។

### ៣.១ សមត្ថភាពមានស្រាប់

មុនពេលចាប់ផ្តើមមេរៀនថ្មី ជាធម្មតាគ្រូត្រូវធ្វើតេស្តដើម្បីវាស់ស្ទង់ ឬរំឭកចំណេះដឹងដែលមានស្រាប់និងចាំបាច់របស់សិស្ស។ ជាញឹកញាប់ គ្រូតែងតែដាក់លំហាត់ឱ្យសិស្សធ្វើជាដៃគូ រួចឱ្យពួកគេឡើងដោះស្រាយលើក្តារខៀន។ វិធីនេះធ្វើឱ្យគ្រូអាចដឹងថាតើពួកគេនៅចងចាំរូបមន្តដែលពួកគេបានរៀនកាលពីមេរៀនមុនដែរឬទេ។ ប៉ុន្តែវិធីនេះមិនទាន់គ្រប់គ្រាន់ក្នុងការវាយតម្លៃចំណេះដឹងមានស្រាប់ និងចាំបាច់របស់សិស្សទាំងអស់គ្នាបានឡើយ។ ដូចនេះគ្រូគួរជ្រើសរើសវិធីណាដែលតម្រូវឱ្យសិស្សចូលរួមបានទាំងអស់គ្នាក្នុងដំណាក់កាលនេះ។ លើសពីនេះទៅទៀត វាជារឿងសំខាន់ដែលយើងមិនគ្រាន់តែសួរថាតើចម្លើយនេះត្រូវ ឬខុសនោះឡើយ។ ប៉ុន្តែនោះជារឿងដែលគ្រូត្រូវឱ្យសិស្សបកស្រាយពីរបៀបរកចម្លើយរបស់ពួកគេ។ ក្នុងករណីសិស្សមានកំហុស វាក៏ជារឿងសំខាន់ដែលគ្រូត្រូវព្យាយាមលើកបង្ហាញនូវចំនុចដែលសិស្សទាល់គំនិត ហើយជួយសម្របសម្រួលពួកគេឱ្យរកចម្លើយបានដោយខ្លួនឯង(Mooney, 2009)។ គ្រូគួរប្រើប្រាស់សម្ភារឧបទេស ឬរូបតំណាងសម្បូរបែបដើម្បីបង្ហាញ។

### ៣.២ ការបង្រៀន

ក្នុងអំឡុងពេលដំណើរការបង្រៀន វិធីវាយតម្លៃត្រូវបានប្រើជាសំណួរយ៉ាងសាមញ្ញបំផុតតាមលំដាប់នៃចំណេះដឹងរបស់សិស្ស។ ប៉ុន្តែវាជារឿងសំខាន់ណាស់ដែលគ្រូត្រូវគិតពីកម្រិត និងប្រភេទសំណួរ។ គួរចងចាំថា នៅពេលសួរសំណួរចង់បានចម្លើយ បាទ/ចាស ឬពេលសួរគ្រាន់តែចង់ឱ្យសិស្សចងចាំនោះគ្រូមិនដឹងពីការយល់ដឹងស៊ីជម្រៅរបស់សិស្សនោះទេ។ ដូច្នេះវាចាំបាច់ណាស់ត្រូវតែឱ្យសិស្សអនុវត្ត វិភាគ សំយោគ និងវាយតម្លៃ។

ឧទាហរណ៍៖

- មុនពេលដោះស្រាយចំណោទ៖ ត្រូវគិតថាចំណោទគេប្រាប់អ្វី? គេសួររកអ្វី? តើយើងដោះស្រាយចំណោទតាមវិធីណា? ខ្លឹមសារចំណោទទាក់ទងនឹងសមត្ថភាពមានស្រាប់អ្វីខ្លះ?
- ក្រោយពេលដោះស្រាយលំហាត់និងចំណោទ៖ ត្រូវគិតថា តើអ្នករកបានចម្លើយតាមវិធីណា? ហេតុអ្វីបានជាអ្នកធ្វើតាមវិធីនេះ?
- នៅពេលផ្ទៀងផ្ទាត់កិច្ចការគ្នាទៅវិញទៅមក៖ ត្រូវសួរគ្នាថា ហេតុអ្វីបានជាអ្នកគិតថាចម្លើយនោះត្រូវ ឬ ខុស?

ចំណុចគួរប្រុងប្រយ័ត្នពេលគ្រូសួរសំណួរៈ

- គ្រូត្រូវតែប្រុងប្រយ័ត្នកុំព្យាយាមឆ្លើយសំណួរដោយខ្លួនឯង ប៉ុន្តែត្រូវជួយសម្របសម្រួលសិស្សឱ្យឆ្លើយបានដោយខ្លួនគេជាមួយការផ្តល់យោបល់ពីគ្រូ និងសិស្សរួមថ្នាក់
- គ្រូត្រូវតែដឹងច្បាស់ថា គាត់ពិតជាបានផ្តល់ពេលវេលាគ្រប់គ្រាន់ដល់សិស្សក្នុងការគិតពីសំណួរ
- គ្រូមិនគួរសួរតែសិស្សពូកែនោះទេ ការធ្វើបែបនេះទើបដឹងពីគំនិតភាន់ច្រឡំដែលសិស្សមាន ហើយអាចជួយគេទាន់ពេលវេលា ជាពិសេសសិស្សរៀនយឺត
- សិស្សទាំងអស់គួរតែអាចឆ្លើយសំណួរបានដោយមានការជួយពីគ្រូ និងសិស្សរួមថ្នាក់។ ព័ត៌មានត្រឡប់ ឬ យោបល់កែលម្អបន្ថែមមួយចំនួនរបស់អ្នកពាក់ព័ន្ធទាំងនេះ អាចជួយបំពេញចំណុចខ្វះខាតរបស់សិស្សបាន
- គ្រូត្រូវកំណត់ឱ្យច្បាស់ថា សំណួរមិនមែនសម្រាប់តែសិស្សស្រីឆ្លើយ ឬ សិស្សប្រុសឆ្លើយនោះទេ។ នៅពេលសិស្សធ្វើបទបង្ហាញ គ្រូត្រូវតែដឹងឱ្យច្បាស់ថាតើ សិស្សទាំងអស់មានឱកាសបង្ហាញនូវការយល់ដឹងរបស់គេបានកម្រិតណា
- ប្រសិនបើសិស្សមានកំហុស នោះត្រូវឱ្យគេដឹងពីមូលហេតុនៃកំហុសរបស់គេ។ វាមិនគ្រប់គ្រាន់ទេបើគ្រាន់តែឱ្យគេនិយាយបាទ/ចាស ឬ ហៅសិស្សដទៃឡើងឆ្លើយ នោះត្រូវឱ្យគេយល់ច្បាស់នូវចម្លើយទាំងនោះផងដែរ។ ដូចគ្នានេះដែរ ប្រសិនបើសិស្សគ្រាន់តែប្រាប់ក្បួន នោះវាមិនគ្រប់គ្រាន់ទេ ត្រូវឱ្យគេធ្វើការបកស្រាយឱ្យបានច្បាស់លាស់ ដោយប្រើរូបតំណាង ឬ ទំនាក់ទំនងខ្លឹមសារពាក់ព័ន្ធ ទើបអ្នកអាចដឹងច្បាស់ថាពួកគេពិតជាយល់ពីខ្លឹមសារមេរៀនបានច្បាស់លាស់
- តាមរយៈការសួរសំណួរដែលមានពាក្យថា ហេតុអ្វី.....? តើ.....ដូចម្តេច? អ្នកអាចរកឃើញនូវអ្វីដែលជាគំនិតរបស់សិស្សក្នុងការយល់ដឹងលើប្រធានបទ គំនិតភាន់ច្រឡំដែលសិស្សមាន និងជួយបំបាត់គំនិតភាន់ច្រឡំទាន់ពេលវេលា។

## ៣.៣ ការអនុវត្ត

ក្នុងដំណាក់កាលអនុវត្ត សិស្សនឹងមានឱកាសធ្វើកិច្ចការកាន់តែឯករាជ្យឡើង ហើយអាចប្រើចំណេះដឹង និងបំណិនដែលពួកគេបានរៀន។ ដោយសារសិស្សធ្វើកិច្ចការដោយខ្លួនឯង គ្រូមានឱកាសវាយតម្លៃសិស្សម្នាក់ៗ។ ការអនុវត្តក៏អាចផ្តល់ឱ្យគ្រូនូវភាពសមគួរក្នុងការញែកភាពខុសគ្នារវាងការយល់ដឹងរបស់សិស្ស។ ព័ត៌មានបន្ថែមស្តីពីភាពខុសគ្នានៃការយល់ដឹងរបស់សិស្សនឹងត្រូវផ្តល់ក្នុងជំពូក៥។

# ជំពូក៤ ៖ វិធីវាយតម្លៃ

## ៤.១ បណ្ណភ្លើងសញ្ញាចរាចរ



**សេចក្តីផ្តើម**

ពេលគ្រូវាយតម្លៃដោយប្រើបណ្ណភ្លើងសញ្ញាចរាចរគ្រូអាចដឹងពីចំណេះដឹងរបស់សិស្សដោយផ្អែកលើការប្រតិបត្តិអំឡុងពេលដំណើរការសកម្មភាព ដែលខុសពីការវាយតម្លៃចុងបញ្ចប់។ គ្រូប្រើលទ្ធផលនៃការឆ្លើយរបស់សិស្សដើម្បីវាស់ស្ទង់ពីសមត្ថភាពរបស់សិស្ស និងបន្ទាប់មករកវិធីជួយគេឱ្យបានសមស្រប និងទាន់ពេលវេលា ហើយគ្រូមិនប្រើលទ្ធផលនេះក្នុងការផ្តល់ពិន្ទុនោះទេ។ វិធីប្រើបណ្ណភ្លើងសញ្ញាចរាចរគឺជាសកម្មភាពសិស្សមជ្ឈមណ្ឌលដ៏សប្បាយរីករាយមួយ ដែលផ្តល់ព័ត៌មានត្រឡប់ឱ្យគ្រូអំពីកម្រិតយល់ដឹងរបស់សិស្ស។

**វត្ថុបំណង**

- ទទួលព័ត៌មានត្រឡប់បានភ្លាមៗពីការយល់ដឹងរបស់សិស្សបានត្រឹមត្រូវ
- បញ្ជាក់ហេតុផលបានត្រឹមត្រូវ និងជួយសិស្សទាន់ពេលវេលា។

**សម្ភារៈជំនួយ**

សិស្សម្នាក់ៗត្រូវការបណ្ណបីសន្លឹក ពណ៌ក្រហម ពណ៌លឿង និងពណ៌បៃតង។ បណ្ណគប្បីមានទំហំធំល្មមដើម្បីឱ្យគ្រូអាចមើលឃើញច្បាស់។ បណ្ណទាំងនោះគប្បីអ៊ុតប្លាស្ទិក ព្រោះធ្វើឱ្យវាអាចប្រើប្រាស់បានយូរ។




## ដំណើរការបង្រៀន

គ្រូអានប្រយោគឱ្យឮច្បាស់ បន្ទាប់មកសិស្សពិចារណាលើប្រយោគនោះ ក្នុងរយៈពេលមួយកំណត់ រួចលើកបណ្ណដែលបញ្ជាក់ថាគេយល់ស្រប ឬ មិនយល់ស្របចំពោះប្រយោគនោះ តាមការគិតរបស់ពួកគេម្នាក់ៗ ។ សិស្សត្រូវលើកបណ្ណព្រមៗគ្នាក្នុងពេលតែមួយ ដោយមិនលើកតាមគ្នាឡើយ គឺលើកបណ្ណភ្លាមពេលគ្រូឱ្យសញ្ញា។

**សម្គាល់៖**

- បណ្ណពណ៌បៃតង៖ យល់ស្រប
- បណ្ណពណ៌លឿង៖ មានចម្ងល់ មិនច្បាស់ ឬមិនដឹង
- បណ្ណពណ៌ក្រហម៖ មិនយល់ស្របទាំងស្រុង

## ដំបូន្មានសំខាន់ៗ

គ្រូត្រូវគ្រប់គ្រងការពិភាក្សារបស់សិស្សមិនឱ្យចាកចេញឆ្ងាយពីប្រធានបទ (VVOB, 2012)។

ពេលសិស្សបដិសេធ ឬមិនយល់ស្រប គ្រូត្រូវឱ្យសិស្សបកស្រាយហេតុផល។ ប្រសិនបើកិច្ចការនោះជាលំហាត់ គ្រូត្រូវឱ្យសិស្សបង្ហាញពីរបៀបដែលគេដោះស្រាយ។

**ដំបូន្មានអំពីសមធម៌**

សិស្សប្រុស និងសិស្សស្រី៖ បញ្ចេញមតិយោបល់

**ឧទាហរណ៍៖ដកស្រង់ពីសៀវភៅសិក្សាគោលបឋមសិក្សា ថ្នាក់ទី៦**

មេរៀន៖ ភាគរយ

ការប្រើបណ្ណភ្លើងសញ្ញាចរាចរក្នុងជំហានទី2 និងទី4 ដើម្បីធ្វើតេស្តសមត្ថភាពមានស្រាប់របស់សិស្ស គ្រូផ្តល់ឧទាហរណ៍ដល់សិស្សសម្រាប់ដោះស្រាយដូចខាងក្រោម៖

១.ចូរប្តូរភាគរយ ទៅជាប្រភាគបង្រួមមិនបាន




២. ចូរប្តូរប្រភាគទៅភាគរយ




**សកម្មភាពអនុវត្ត**

- ចែកបណ្ណភ្លើងសញ្ញាចរាចរដល់សិស្សម្នាក់ៗ។

**ដំណើរការបង្រៀន**

- គ្រូសរសេរលំហាត់ដាក់លើក្តារខៀន
- ឱ្យសិស្សពីរនាក់ឡើងដោះស្រាយលំហាត់នៅលើក្តារខៀន
- ឱ្យសិស្សសង្កេតចម្លើយនៅលើក្តារខៀនត្រូវ ឬខុស
- បើសិស្សណាយល់ស្រប ត្រូវលើកបណ្ណពណ៌បៃតង
- បើសិស្សណាមានចម្ងល់ ឬមិនដឹង លើកបណ្ណពណ៌លឿង
- បើសិស្សណាមិនយល់ស្រប លើកបណ្ណពណ៌ក្រហម
- ឱ្យសិស្សបញ្ជាក់ហេតុផលលើចម្លើយនីមួយៗតាមបណ្ណពណ៌របស់ខ្លួនដោយប្រើសំណួរ៖ ហេតុអ្វីបានជាប្អូនប្រើវិធីនេះដើម្បីដោះស្រាយ?

**ឧទាហរណ៍៖ ដកស្រង់ពីសៀវភៅសិក្សាគោលបឋមសិក្សា**

មេរៀន៖ ប្រភាគ

អនុវត្តក្នុងជំហានទី2 និងទី4គ្រូដាក់លំហាត់ វិធីបូក និងដកប្រភាគដែលមានភាគបែងដូចគ្នាឱ្យសិស្ស គណនាដូចខាងក្រោម៖

ក. ចូរគណនាផលបូកប្រភាគខាងក្រោម៖

$\frac{3}{7}+\frac{1}{7}=?$

$\frac{11}{15}+\frac{1}{15}=?$

$\frac{9}{22}+\frac{7}{22}=?$

$\frac{12}{20}+\frac{6}{20}=?$

ខ. ចូរគណនាផលដកប្រភាគខាងក្រោម៖

$\frac{4}{5}-\frac{1}{5}=?$

$\frac{5}{6}-\frac{3}{6}=?$

$\frac{13}{35}-\frac{11}{35}=?$

**សកម្មភាពអនុវត្ត**

- គ្រូសរសេរលំហាត់បូក ដកប្រភាគដាក់លើក្ដារខៀន
- ចែកបណ្ណភ្លើងសញ្ញាចរាចរឱ្យសិស្សម្នាក់ៗ
- ឱ្យសិស្សឡើងគណនានៅលើក្ដារខៀន
- បើសិស្សណាយល់ស្របលើក បណ្ណពណ៌បៃតង បើមិនយល់ស្រប លើកបណ្ណពណ៌ក្រហម និងបើមិនដឹង លើកបណ្ណពណ៌លឿង
- ឱ្យសិស្សបញ្ជាក់ហេតុផលលើចម្លើយនីមួយៗ
- សំណួរបំផុស៖ ហេតុអ្វីបានជាប្អូនធ្វើតាមវិធីនេះ? ចូរបញ្ជាក់ហេតុផលឱ្យបានច្បាស់លាស់
- កំណត់សម្គាល់៖ ព្យាយាមប្រើរូបតំណាងផ្សេងៗគ្នាដើម្បីពន្យល់ការធ្វើប្រមាណវិធីប្រភាគ
- ផ្ដល់ឱកាសឱ្យសិស្សបកស្រាយការជ្រើសរើសរបស់ខ្លួនតាមពណ៌នីមួយៗ
- ក្រោយពេលស្ដាប់ការបកស្រាយរបស់សិស្ស គ្រូត្រូវឱ្យសិស្សលើកបណ្ណម្ដងទៀត។

## ៤.២ ព្យុះគំនិត



### សេចក្តីផ្តើម

ព្យុះគំនិតគឺជាសកម្មភាពសម្រាប់ដោះស្រាយបញ្ហា ជាក្រុមដ៏មានប្រយោជន៍ និងប្រសិទ្ធភាពដោយមានការចូលរួមគំនិតជាច្រើនពីសមាជិកក្រុម។ ការផ្តល់មតិយោបល់របស់សមាជិកក្រុមម្នាក់ៗអាចជួយឱ្យសមាជិកផ្សេងទៀតនឹកឃើញគំនិតថ្មីៗជាបន្តបន្ទាប់សម្រាប់ជាពន្លឺក្នុងការដោះស្រាយបញ្ហា។

### វត្ថុបំណង

- ប្រមូលចំណេះដឹងមានស្រាប់របស់សិស្សដែលទាក់ទងជាមួយមេរៀនថ្មី
- បំផុសគំនិតច្នៃប្រឌិត
- ប្រែក្លាយការចង់ចេះចង់ដឹងទៅជាការចោទសំណួរបែបគណិតវិទ្យា
- បង្កើតគំនិតពីរបៀបដោះស្រាយចំណោទផ្សេងៗដែលអាចមាន
- បង្កើតគំនិតក្នុងរយៈពេលខ្លី។

### ដំណើរការបង្រៀន

ការណែនាំពីមួយជំហានទៅមួយជំហានឱ្យបានច្បាស់លាស់មានសារៈសំខាន់ណាស់។ គ្រូអាចអនុវត្តតាមគោលការណ៍ណែនាំដូចតទៅ៖

- លើកទឹកចិត្តសិស្សឱ្យគិត (សរសេរពាក្យគន្លឹះ សំណួរបំផុសមួយនៅលើក្តារខៀន ឬលើផ្ទាំងក្រដាសធំ)
- ចែកសិស្សជាក្រុមតូចៗ ហើយសិស្សម្នាក់ក្នុងក្រុមនីមួយៗត្រូវបានចាត់តាំងធ្វើជាអ្នកកត់ត្រារាល់គំនិតទាំងឡាយរបស់ក្រុម
- កំណត់ពេលវេលាជាក់លាក់សម្រាប់សកម្មភាពព្យុះគំនិត (អតិបរមា 5នាទី)
- ដើម្បីធានារាល់គំនិតដែលសិស្សអាចរកបាន អ្នកអាចកំណត់ចំនួនគំនិតអប្បបរមាដែលគេត្រូវរក
- បន្ទាប់ពីសិស្សធ្វើព្យុះគំនិតចប់ ទុកពេលឱ្យក្រុមនីមួយៗតម្រៀបគំនិតទាំងនោះតាមលំដាប់នៃភាពសំខាន់។

**ដំបូន្មានអំពីសមធម៌**

សិស្សប្រុស និងសិស្សស្រី៖ ចូលរួមយ៉ាងសកម្មទាំងអស់គ្នា

### សំណូមពរ

វិធីដាក់ឈ្មោះក្រុមជាប្រភេទនៃសកម្មភាពព្យុះគំនិតមួយដែលបង្ហាញរចនាសម្ព័ន្ធបន្ថែមទៀត សម្រាប់លំនាំនៃការបង្រៀន។ គ្រូត្រូវធានាថាអ្នកចូលរួមទាំងអស់មានឱកាសបញ្ចេញមតិគ្រប់ៗគ្នា ហើយអាចប្រើដើម្បី បង្កើតជាបញ្ជីគំនិតដែលអាចធ្វើចំណាត់ថ្នាក់តាមភាពសំខាន់បាន។ សមាជិកក្រុមម្នាក់ៗត្រូវសរសេរគំនិតរបស់គេចូលក្នុងក្រដាសរៀងៗខ្លួន។ បន្ទាប់មកសមាជិកក្រុមម្នាក់ ដែលមាននាទីជាអ្នកសម្របសម្រួលសុំឱ្យសមាជិកក្រុមម្នាក់ៗអានគំនិតមួយក្នុងចំណោមគំនិតដែលគេបានសរសេរ។ អ្នកសម្របសម្រួលសរសេរគំនិតរបស់សមាជិក

ក្រុមម្នាក់ៗនៅលើក្រដាសផ្ទាំងធំ។ បន្ទាប់មកសមាជិកក្រុមម្នាក់ៗ ចម្លងបញ្ជីគំនិតចុងក្រោយរបស់ក្រុមចូលក្នុងក្រដាសមួយផ្សេងទៀត ដោយរៀបតាមលំដាប់អាទិភាពគំនិត (VVOB, 2012)។

**ឧទាហរណ៍៖ ដកស្រង់ពីសៀវភៅសិក្សាគោលបឋមសិក្សា**

មេរៀន៖ ប្រភាគ

គ្រូសរសេរប្រភាគ $\frac{3}{4}$ លើក្តារខៀន រួចចែកក្រដាសមួយសន្លឹកឱ្យសិស្ស/ក្រុមសិស្ស។ សិស្សត្រូវសរសេរ ពីអ្វីដែលគេបានដឹងទាក់ទងនឹងប្រភាគនេះ។ សកម្មភាពនេះមានសារៈសំខាន់ក្នុងការវាយតម្លៃចំណេះដឹងមានស្រាប់របស់សិស្សលើគំនូសតាងប្រភាគ។ ប្រភេទសំណួរព្យុះគំនិតមួយទៀតគឺ ឱ្យសិស្សសរសេរពីការប្រើប្រាស់ប្រភាគក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។ សំណួរដំបូងគឺ៖ ហេតុអ្វីបានជាអ្នកចាំបាច់ ត្រូវរៀនអំពីប្រភាគ? តើយើងប្រើប្រាស់ប្រភាគក្នុងជីវភាពរស់នៅប្រចាំថ្ងៃដោយរបៀបណា?

**ឧទាហរណ៍៖** ប្រើប្រាស់ប្រភាគទាក់ទងនឹងជីវភាពប្រចាំថ្ងៃ

សំណួរ៖ **តើមានអ្វីខ្លះដែលទាក់ទងទៅនឹងប្រភាគនៅក្នុងជីវភាពប្រចាំថ្ងៃរបស់ប្អូនៗ?**

ចូររកឧទាហរណ៍ដែលទាក់ទងនឹងប្រភាគនៅក្នុងជីវភាពប្រចាំថ្ងៃឱ្យបានយ៉ាងតិចចំនួន5។

*ចម្លើយរំពឹងទុក៖*

1. ការបែងចែកប្រភេទវត្ថុ ឬ បរិមាណតែមួយជាចំណែកស្មើៗគ្នា។ ចំណែកដែលគេយកធៀបទៅនឹងចំណែកទាំងអស់ជាប្រភាគ។
2. ចំនួនសិស្សដែលចូលចិត្តរៀនគណិតវិទ្យាក្នុងថ្នាក់មួយជាប្រភាគ។
3. ការបែងចែកផ្ទៃដីដាំដំណាំមួយកន្លែងប្រភេទខុសៗគ្នាជាប្រភាគ។
4. មាត្រដ្ឋានផែនទីមួយជាប្រភាគ។
5. ការពុះផ្លែឪឡឹកមួយ ជាចំណែកស្មើៗគ្នាជាប្រភាគ។

☞ ការយកមួយ ឬច្រើនចំណែកធៀបនឹងចំណែកទាំងអស់ជាប្រភាគ។

**<u>ការបកស្រាយឧទាហរណ៍</u>**

១.



២. ចំនួនសិស្សដែលចូលចិត្តរៀនគណិតវិទ្យា(តាមជាក់ស្តែង)

៣. បែងចែកដីដាំដំណាំ៖

-ដីដាំល្ហុងដោយពណ៌ខៀវមាន 5% ស្មើ $\frac{1}{20}$

-ដីដាំស្រូវតាងដោយពណ៌ស្វាយមាន45% ស្មើ $\frac{9}{20}$

- ដីដាំពោតតាងដោយពណ៌បៃតងចាស់មានស្មើ40% ស្មើ $\frac{2}{5}$
- ដីដាំសណ្តែកបាយតាងដោយពណ៌ក្រហមមាន10% ស្មើ $\frac{1}{10}$




៤. គំនូរផែនទីប្រទេសកម្ពុជា ( មាត្រដ្ឋានរបស់ផែនទី $\frac{1}{100000}$ )

៥. ការពុះផ្លែឪឡឹកជា 4 ចំណែកស្មើៗគ្នារួចចែកឱ្យសិស្ស4នាក់ដែលម្នាក់ៗ ទទួលបាន $\frac{1}{4}$ នៃផ្លែឪឡឹកទាំងមូល។





សេចក្តីសន្និដ្ឋាន៖

សិស្សមានសមត្ថភាពក្នុងការពិភាក្សាជាមួយដៃគូពីឧទាហរណ៍នៃប្រភាគដែលបានជួបប្រទះនៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់ខ្លួនព្រមទាំងអនុវត្តដោយប្រើប្រាស់រូបតាងប្រភាគនោះ។

## ៤.៣ តុក្កតាគំនិត

### សេចក្តីផ្តើម

តុក្កតាគំនិតជារូបគំនូរសាមញ្ញដែលអមដោយគំនិត ឬ ការយល់ឃើញពីបញ្ហាពាក់ព័ន្ធនឹងគណិតវិទ្យាដែលមាន នៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។

វត្ថុបំណងសំខាន់របស់តុក្កតាគំនិតគឺជួយបំផុសសិស្សឱ្យគិត ពិភាក្សា ចោទសំណួរ អង្កេត និងផ្តល់ហេតុផល។ វិធីនេះមានលក្ខណៈស៊ីជម្រៅជាងសំណួរពហុជ្រើសរើស។ វាជាកត្តាជំរុញឱ្យសិស្សចូលរួមធ្វើសកម្មភាពគិត និងស្រាវជ្រាវ។ ចម្លើយទាំងអស់តំណាងឱ្យគំនិតភាន់ច្រឡំដែលកើតមានឡើងសម្រាប់សិស្សហើយគ្រូគួរយកចិត្តទុកដាក់ដោះស្រាយវាក្នុងពេលបង្រៀន។




សូមកត់សម្គាល់ថារាល់ចម្លើយទាំងអស់ក្នុងរូបគំនូរតុក្កតាគំនិតមានលក្ខណៈស្រដៀងគ្នា សិស្សត្រូវព្យាយាមជ្រើសរើស និងបញ្ជាក់គំនិតឱ្យបានល្អបំផុតលើចម្លើយនោះ។ ដំណើរការនៃភាពចម្រូងចម្រាសលើការយល់ឃើញផ្សេងៗគ្នានេះគឺជាទិដ្ឋភាពសំខាន់នៃការបង្កើនចំណេះដឹង។ ហេតុនេះហើយ តុក្កតាគំនិតជាវិធីដ៏សក្តិសមសម្រាប់ការបង្រៀនតាមគោលវិធីសិស្សមជ្ឈមណ្ឌល។

គ្រូអាចប្រើវិធីនេះនៅពេលចាប់ផ្តើម ឬចុងបញ្ចប់នៃមេរៀន។ នៅពេលចាប់ផ្តើមមេរៀនគ្រូអាចប្រើគំនូតុក្កតាគំនិតនេះដើម្បីបំផុសគំនិតបង្កើតបរិបទមួយ។ នៅចុងបញ្ចប់នៃមេរៀន គ្រូអាចវាយតម្លៃការយល់ដឹងរបស់សិស្សលើវត្ថុបំណងនៃមេរៀន។ ការប្រើប្រាស់សម្ភារឧបទេសជួយក្នុងការបញ្ជាក់ថាតើអំណះអំណាងណាមួយត្រឹមត្រូវ ឬក៏ខុសនៅក្នុងតុក្កតាគំនិត។

**វត្ថុបំណង**

គ្រូសម្រេចវត្ថុបំណងខុសៗគ្នាអាស្រ័យលើរបៀបដែលគាត់ត្រូវប្រើគំនូរតុក្កតាគំនិតនៅក្នុងថ្នាក់រៀន ដូចជា៖

- រកឱ្យឃើញ ឬ កំណត់នូវគំនិតរបស់សិស្សបានច្បាស់លាស់ ហេតុនេះគ្រូអាចដឹងច្បាស់ ពីគំនិតភាន់ច្រឡំចម្រូងៗបានត្រឹមត្រូវ
- ប្រកួតប្រជែង អភិវឌ្ឍការគិត និងការយល់ឃើញ
- បង្ហាញគំនិតផ្សេងៗគ្នា
- ពង្រឹងចំណេះដឹងគណិតវិទ្យារបស់សិស្ស។

**សម្ភារៈ**

- គំនូរតុក្កតាគំនិត (សូមមើលឧបសម្ព័ន្ធ)
- ក្រដាសA4 (សម្រាប់សិស្សកត់ត្រា)
- សម្ភារឧបទេសសម្រាប់ពន្យល់ខ្លឹមសារមេរៀន។

**ដំណើរការបង្រៀន**

គ្រូអាចប្រើគំនូរតុក្កតាគំនិតក្នុងការបង្រៀនបានដោយប្រើរួមជាមួយសកម្មភាពសិស្សមជ្ឈមណ្ឌលផ្សេងៗគ្នា (VVOB, 2012)។

## ៤.៣.១ ការគិតជាបុគ្គល

**សេចក្តីផ្តើម**

គ្រូអាចបង្ហាញតុក្កតាគំនិតដល់សិស្សតាមរយៈវិធីគិតជាបុគ្គល។ វិធីនេះចំណាយពេលតិច ប៉ុន្តែសិស្សមិនមានភាពសកម្មក្នុងការចូលរួមសកម្មភាពពិភាក្សាជាក្រុម។

**វត្ថុបំណង**

- បំផុសការពិភាក្សារបស់សិស្សអំពីការគិតតាមបែបគណិតវិទ្យា
- ជំរុញការប្រើប្រាស់ចំណេះដឹងមានស្រាប់របស់សិស្សដើម្បីរកឱ្យឃើញ និងកែតម្រូវគំនិតភាន់ច្រឡំរបស់សិស្ស។

**សម្ភារៈជំនួយ**

- គំនូរតុក្កតាគំនិត ។

**ដំណើរការបង្រៀន**

- គ្រូបង្ហាញគំនូរតុក្កតាគំនិតដល់សិស្ស និងពន្យល់អំពីស្ថានភាព
- ទុកពេលវេលាសមរម្យឱ្យសិស្សម្នាក់ៗឆ្លុះបញ្ចាំងការយល់ឃើញរៀងៗខ្លួន ដោយគេម្នាក់ៗអានគោលគំនិតទាំងអស់ក្នុងគំនូរតុក្កតាគំនិត និងព្យាយាមឆ្លើយសំណួរខាងក្រោម៖
    - តើអ្នកយល់ស្របនឹងគំនិត ឬផ្នែកណាមួយ?

- តើអ្នកអាចមានគំនិតត្រឹមត្រូវលើសពីមួយ ឬ ទេ?
  *ហេតុអ្វីបានជាសំណួរនេះសំខាន់? សិស្សចាំបាច់ត្រូវគិតពីមូលហេតុដែលនាំឱ្យចម្លើយណាមួយត្រូវ ឬខុស។ ជួនកាល គោលគំនិតមួយអាចត្រឹមត្រូវដោយផ្នែកប៉ុណ្ណោះ។*

- គ្រូអាចត្រួតពិនិត្យការគិតរបស់សិស្សភ្លាមៗ (ដូចជាតាមរយៈការលើកដៃ ឬប្រើបណ្ណសម្រាប់បោះឆ្នោត)
- រៀបចំការពិភាក្សាជារួមក្នុងថ្នាក់ទាំងមូល និងព្យាយាមពិភាក្សាចម្លើយទាំងអស់ដោយប្រើសំណួរបំផុស ដើម្បីជួយសិស្សឱ្យបកស្រាយហេតុផលបានត្រឹមត្រូវ(VVOB, 2012)។

## ៤.៣.២ ពិភាក្សាក្រុម

**ដំបូន្មានអំពីសមធម៌**

សិស្សប្រុស និងសិស្សស្រីៈ ធ្វើការរួមគ្នា (ដៃគូ ឬក្រុម)

### សេចក្តីផ្តើម

អ្នកអាចទទួលបានប្រសិទ្ធភាពខ្ពស់បំផុតក្នុងការប្រើរូបគំនូរតុក្កតាគំនិតតាមរយៈការផ្តល់ឱកាសឱ្យសិស្សពិភាក្សាជាក្រុម។ សកម្មភាពនេះអនុញ្ញាតឱ្យសិស្សពិភាក្សាគ្នាលើការយល់ឃើញរបស់គេជាមួយមាជិកក្រុម។ ពួកគេអាចរៀនសូត្របកស្រាយហេតុផល និងស្តាប់ការយល់ឃើញរបស់អ្នកដទៃ។ ការរៀនសូត្រតាមបែបសហការប្រភេទនេះ គឺជាបទពិសោធមួយដ៏មានអត្ថប្រយោជន៍។

### វត្ថុបំណង

- រកឱ្យឃើញនូវគំនិតភាន់ច្រឡំរបស់សិស្ស
- ពង្រីកចំណេះដឹងរបស់សិស្ស។

### សម្ភារៈជំនួយ

- គំនូរតុក្កតាគំនិត (បោះពុម្ពលើក្រដាស A3 ឬA4)។

### ដំណើរការបង្រៀន

- ចែកសិស្សជាក្រុមតូចៗហើយចែកផ្ទាំងគំនូរតុក្កតាគំនិតដល់ក្រុមនីមួយៗ
- ទុកពេលវេលាឱ្យសិស្សគិតរៀងៗខ្លួន ថាគោលគំនិតមួយណាដែលត្រូវនឹងការយល់ឃើញរបស់គេ (ប្រហែល២នាទី)
- លើកទឹកចិត្តឱ្យពួកគេពិភាក្សាគ្នាដើម្បីស្វែងរកគំនិតរួម។ ប្រសិនបើការពិភាក្សារបស់ពួកគេអាចឈានដល់ការយល់ស្របគ្នាយ៉ាងឆាប់រហ័ស នោះពួកគេត្រូវរកហេតុផលសម្រាប់បកស្រាយដល់ក្រុមផ្សេងទៀត ដែលមានការយល់ឃើញផ្សេងពីក្រុមខ្លួន (ប្រហែល10នាទី)

- ឱ្យសិស្សផ្ដល់ព័ត៌មានត្រឡប់គ្នាទៅវិញទៅមក ដើម្បីស្វែងយល់ពីការយល់ឃើញរបស់សិស្សទាំងអស់នៅក្នុងថ្នាក់។ គ្រូអាចឱ្យសិស្សលើកដៃ ប្រើបណ្ណភ្លើងសញ្ញាចរាចរ...
- ផ្ដល់ឱកាសឱ្យក្រុមដែលមានការយល់ឃើញផ្សេងៗពីគ្នាប្រាប់ពីហេតុផលរបស់គេរៀងខ្លួន និងចូលរួមពិភាក្សាទាំងអស់គ្នា ដើម្បីរកការយល់ឃើញមួយចំនួនដែលសមហេតុផលជាងគេ និងព័ត៌មានបន្ថែម ដែលត្រូវការដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវនៃការយល់ឃើញទាំងនោះ
- គ្រូប្រមូលគំនិតទាំងអស់បញ្ចូលគ្នា និងផ្ដល់ជាសេចក្ដីសង្ខេបដ៏ច្បាស់លាស់មួយអំពីប្រធានបទខាងដើម។ សួរសិស្ស ថាតើគេចង់ផ្លាស់ប្ដូរការយល់ឃើញពីដំបូងរបស់គេ ឬទេ(VVOB, 2012)។

## ៤.៤ ការពិនិត្យឡើងវិញជាមួយដៃគូ



**សេចក្ដីផ្ដើម**

ការពិនិត្យឡើងវិញជាមួយដៃគូ ជាវិធីមួយជំរុញឱ្យមានទំនាក់ទំនងរវាងសិស្ស និងសិស្ស។

**វត្ថុបំណង**

- មានទំនាក់ទំនងល្អនៅក្នុងថ្នាក់រៀនតាមរយៈការងារដៃគូ និងក្រុមសិស្សក្នុងថ្នាក់ទាំងមូល
- ទទួលបានព័ត៌មានត្រឡប់ និងវាយតម្លៃច្បាស់លាស់តាមរយៈការផ្ដល់មតិពីមិត្តភក្ដិ
- ចែករំលែកបទពិសោធគ្នាទៅវិញ ទៅមក (យុទ្ធវិធី បញ្ហា) ការពិភាក្សាក្នុងក្រុមធំ។

**សម្ភារៈជំនួយ**

- ក្រដាស

**ដំណើរការបង្រៀន**

- សិស្សដោះស្រាយលំហាត់ ឬចំណោទ ជាការងារដៃគូ និងសរសេរជំហាននីមួយៗរហូតឈានដល់ចម្លើយ
- ប្រគល់ដំណោះស្រាយរបស់ខ្លួនទៅដៃគូផ្សេងទៀត ដើម្បីឱ្យគេផ្ដល់យោបល់ ។ គ្រូត្រួតពិនិត្យតាមដៃគូដោយយកចិត្តទុកដាក់លើចម្លើយ ការផ្ដល់យោបល់ និងការប្រើប្រាស់វាក្យសព្ទ គណិតវិទ្យាផងដែរ។ បើសិនមានសិស្សណាចូលរួមតិច គ្រូត្រូវជំរុញពួកគេ ដោយសួរសំណួរ ឬ ឱ្យគេឡើងបូកសរុបចុងក្រោយ។
- រៀបចំការពិភាក្សារួមក្នុងថ្នាក់ទាំងមូល (Ontario, 2010)។

**ឧទាហរណ៍ដកស្រង់ពីសៀវភៅសិក្សាគោលបឋមសិក្សា** (ថ្នាក់ទី6)

មេរៀន៖ ការប្រាក់សាមញ្ញ និងការបង់រំលស់

**ចំណោទ៖**

ម៉ូតូមួយគ្រឿងថ្លៃ1000ដុល្លារ។ មីងសំនិងពូសនទិញម៉ូតូនេះដោយបង់រំលស់110ដុល្លារក្នុងមួយខែហើយត្រូវបង់12ខែ។ រកប្រាក់ដែលគាត់ត្រូវបង់បន្ថែមពីលើតម្លៃដើមរួចគិតជាភាគរយ។

១. ឱ្យសិស្សរកវិធីដោះស្រាយ

២. គ្រូតពិនិត្យកិច្ចការរបស់សិស្ស

តើយើងអាចដោះស្រាយចំណោទនេះតាមវិធីណាខ្លះ?

- ប្រើតារាង
- ប្រើដ្យាក្រាម
- គណនា...

៣. ប្តូរកិច្ចការគ្នាទៅវិញទៅមក

- ឱ្យសិស្សកែលម្អកិច្ចការគ្នាទៅវិញទៅមក និងផ្តល់យោបល់លើវិធីដោះស្រាយផ្សេងៗទៀតដល់ដៃគូរបស់គេ
- ប្រគល់កិច្ចការដើមឱ្យទៅដៃគូហើយដោះស្រាយតាមវិធីដែលដៃគូបានណែនាំ។

៤. ការពិភាក្សាក្នុងថ្នាក់

- ឱ្យសិស្សយកកិច្ចការដែលពួកគេបានដោះស្រាយមកបិទបង្ហាញនៅលើក្តារខៀន
- ឱ្យសិស្សពិភាក្សាគ្នាលើវិធីដោះស្រាយដែលគេបានបង្ហាញហើយធ្វើការប្រៀបធៀប ដើម្បីកំណត់រកវិធីដោះស្រាយ
- គ្រូធ្វើការសម្របសម្រួល និងសំយោគយកវិធីដែលល្អហើយងាយស្រួលយល់ និងខ្លី។

**សម្គាល់**

១. គ្រូដើរត្រួតពិនិត្យមើលកិច្ចការរបស់សិស្សតាមក្រុម ឬបុគ្គលម្នាក់ៗ

២. បើពិនិត្យឃើញសិស្សក្រុមណាមួយ ឬសិស្សណាម្នាក់ដោះស្រាយចំណោទមិនបានត្រឹមត្រូវ គ្រូត្រូវឱ្យក្រុមឬសិស្សណាដែលធ្វើបានត្រឹមត្រូវមកជួយពន្យល់បន្ថែម។

## ៤.៥ វិធីស្វែងរកដំណោះស្រាយច្រើនបែប

**សេចក្តីផ្តើម**

វិធីនេះជំរុញទំនាក់ទំនងដើម្បីទទួលបានដំណោះស្រាយច្រើនបែប។




**វត្ថុបំណង**

- បង្កើតទំនាក់ទំនងរវាងសិស្ស និងសិស្ស សិស្ស និងគ្រូ ឬ រវាងចំណេះដឹងមានស្រាប់ និងចំណោទបញ្ហា ឬលំហាត់របស់គេ
- គិតដោយច្នៃប្រឌិតរកវិធីដោះស្រាយបញ្ហា(យុទ្ធសាស្រ្តដោះស្រាយច្រើន)
- រកឃើញវិធីងាយៗក្នុងការដោះស្រាយលំហាត់ ឬចំណោទតាមរយៈការគិតដោយច្នៃប្រឌិតនិងប្រៀបធៀបវិធីផ្សេងៗរបស់ពួកគេ។

**សម្ភារៈជំនួយ**

- ក្រដាសA3 ឬ A2 តារាង បន្ទាត់លេខ និងដ្យាក្រាម។

**ដំណើរការបង្រៀន**

- គ្រូដាក់លំហាត់ ឬចំណោទលើក្តារខៀនរួចឱ្យសិស្សអាន និងបំផុសបញ្ហាដើម្បីជាគន្លឹះសម្រាប់ដោះស្រាយលំហាត់ ឬចំណោទ
- ពេលក្រុមនីមួយៗដោះស្រាយលំហាត់ ឬ ចំណោទ គ្រូដើរមើលតាមក្រុម និងសង្កេតមើលយុទ្ធវិធីដោះស្រាយរបស់ពួកគេ។ ផ្អែកលើការសង្កេត គ្រូជ្រើសរើសក្រុមដែលអាចបង្ហាញពីវិធីដោះស្រាយមិនបានគ្រប់គ្រាន់ឡើងបង្ហាញមុនគេ បន្ទាប់មកក្រុមដែលប្រើវិធីដោះស្រាយល្អជាងនេះ បង្ហាញបន្តបន្ទាប់តាមក្រោយ។ លំនាំបែបនេះ ជំរុញឱ្យសិស្សមានការកសាងសមត្ថភាពថ្មី និងយល់ខ្លឹមសារកាន់តែច្បាស់។ ទោះស្ថានភាពបែបណាក៏ដោយគ្រូគប្បីបញ្ជាក់ពីកម្រិតខុសគ្នានៃការប្រើវិធីដោះស្រាយនីមួយៗផងដែរ ដើម្បីលើកទឹកចិត្ត និងពង្រឹងភាពជឿជាក់របស់សិស្ស (Ontario, 2010)។

ឧទាហរណ៍ដកស្រង់ចេញពីសៀវភៅសិក្សាគោលបឋមសិក្សាថ្នាក់ទី5
មេរៀន៖ ប្រភាគ
វិធីបូកប្រភាគដែលមានភាគបែងដូចគ្នា:
១.ចូរគណនាផលបូកប្រភាគដោយបំពេញលេខក្នុងប្រអប់ខាងក្រោម៖

ក. $\frac{3}{7}+\frac{1}{7}=\frac{\square}{\square}$

ខ. $\frac{3}{10}+\frac{4}{10}=\frac{\square}{\square}$

២.ចូរបំពេញលេខក្នុងប្រអប់ខាងក្រោម៖

ក. $\frac{1}{3}+\frac{\square}{\square}=\frac{2}{3}$

ខ. $\frac{\square}{\square}+\frac{1}{3}=\frac{2}{7}$

- បែងចែកសិស្សជាក្រុមតូចៗដែលមានចំនួន៤ ឬ៥នាក់ក្នុងមួយក្រុមៗ
- គ្រូណែនាំសិស្សឱ្យដោះស្រាយដោយប្រើរូបតំណាងផ្សេងៗដូចជា៖ តារាង បន្ទាត់លេខ ដ្យាក្រាម
- គ្រូដើរពិនិត្យ និងសម្របសម្រួលតាមក្រុម ដោយកំណត់ពេលវេលាមួយជាក់លាក់
- សិស្សពិភាក្សាគ្នារកដំណោះស្រាយតាមក្រុមតូច
- ក្រុមដែលបានធ្វើរួចហើយ ត្រូវឡើងបិទលើក្ដារខៀនដោយត្រៀមតំណាងក្រុមម្នាក់ សម្រាប់ធ្វើការបង្ហាញ
- ពេលដែលតំណាងក្រុមនីមួយៗធ្វើការបកស្រាយ សិស្សទាំងអស់ត្រូវចូលរួមផ្ដល់ជាយោបល់ដោយយកចិត្តទុកដាក់ខ្ពស់បំផុត ព្រមទាំងមានការសម្របសម្រួលពីគ្រូជាប្រចាំ
- គ្រូ និងសិស្សធ្វើការសន្និដ្ឋាន វាយតម្លៃ និងបូកសរុបលទ្ធផលរបៀបដោះស្រាយទាំងនោះ។

## ៤.៦ ល្បែងជេអូផាឌី (Jeopardy)

**សេចក្ដីផ្ដើម**

ជេអូផាឌីគឺជាល្បែងសិក្សាដែលប្រើដើម្បីវាយតម្លៃ និងពង្រឹងចំណេះដឹងសិស្ស ហើយវាគឺជាល្បែងមួយដែលជួយជំរុញឱ្យមានការអភិវឌ្ឍលទ្ធផលសិក្សាផងដែរ។ តាមរយៈល្បែង ជេអូផាឌី សិស្សកសាងសមត្ថភាពថ្មីៗបានថែមទៀតដោយមានការលើកទឹកចិត្ត ការចែករំលែក បទពិសោធន៍ និងការជួយកែលម្អគំនិតភាន់ច្រឡំគ្នាទៅវិញទៅមក។

**វត្ថុបំណង**

- បង្ហាញសមត្ថភាពឆ្លើយតបយ៉ាងសកម្មទៅនឹងប្រធានបទនៃសំណួរនីមួយៗ ប្រកបដោយការប្រកួតប្រជែង

**សម្ភារៈជំនួយ**

- តារាងពិន្ទុ បណ្ណលំហាត់ ឆ្នោតលេខ ក្ដារឆ្នួន ហ្វឺត...។

**ដំណើរការបង្រៀន**

គ្រូសង្កេតសិស្សដើម្បីឱ្យដឹងថា សមាជិកក្រុមម្នាក់ៗមានឱកាសចូលរួមពិភាក្សាគ្រប់គ្នា និងវិធីដែលសិស្សដោះស្រាយបញ្ហា ឬលំហាត់។

- ចែកសិស្សឱ្យធ្វើការងារជាក្រុមដែលមួយក្រុមមានគ្នា3 ឬ4នាក់ ហើយជ្រើសរើសតំណាងម្នាក់ ក្នុងក្រុមចាប់លេខរៀងយកអាទិភាពឆ្លើយសំណួរ
- គ្រូបង្ហាញប្រអប់សំណួរ និងតារាងពិន្ទុនៅលើក្ដារខៀន
- គ្រូណែនាំសិស្សពីតារាងពិន្ទុ ដោយបញ្ជាក់ពីលំដាប់នៃពិន្ទុ និងកម្រិតនៃសំណួរ (សំណួរ កាន់តែលំបាក ពិន្ទុកាន់តែខ្ពស់)
- ក្រុមដែលចាប់បានលេខរៀងទី1 ត្រូវតែជ្រើសរើសសំណួរទី1 ក្នុងប្រធានបទណាមួយមកឆ្លើយ បកស្រាយក៏បាន
- តំណាងក្រុមអានសំណួរឱ្យឮៗ
- ប្រសិនបើក្រុមដំបូងឆ្លើយសំណួរបានត្រឹមត្រូវ ក្រុមនេះអាចជ្រើសរើសសំណួរបន្ទាប់ពីសំណួរមុន ឬសំណួរដំបូងគេនៃប្រធានបទណាមួយ
- ប្រសិនក្រុមដំបូងឆ្លើយសំណួរមិនបានត្រឹមត្រូវ ក្រុមបន្ទាប់ត្រូវឆ្លើយសំណួរនោះ ដោយមិនទុកពេលវេលាឱ្យគិតទៀតទេ
- ក្រុមនីមួយៗមានសិទ្ធិឆ្លើយបានតែពីរសំណួរក្នុងមួយជុំ
- ក្នុងករណីនៅសល់សំណួរដែលគ្រប់ក្រុមមិនទាន់រកចម្លើយឃើញ គ្រូផ្ដល់ចម្លើយ
- ក្រុមដែលឆ្លើយត្រូវ នឹងទទួលបានពិន្ទុ(ដូចតារាងខាងក្រោម)
- ល្បែងនេះត្រូវបានបញ្ចប់នៅពេលដែលសិស្សឆ្លើយសំណួរបានត្រឹមត្រូវទាំងអស់ ហើយក្រុមដែលទទួលបានពិន្ទុច្រើនជាងគេ គឺជាអ្នកឈ្នះ ឬ ក៏គ្រូអាចបញ្ចប់ល្បែងតាមរយៈពេលដែលបានកំណត់ ដោយមិនបានចាំរហូតដល់ឆ្លើយសំណួរអស់នោះទេ ។
- គ្រូបូកសរុបពិន្ទុរបស់ក្រុមនីមួយៗ ដើម្បីរកឱ្យឃើញក្រុមទទួលជ័យជម្នះក្នុងការលេងល្បែងនេះ។

**សម្គាល់ៈ**

- ការចាប់សំណួរក្នុងប្រធានបទនីមួយៗមិនត្រូវរំលងលំដាប់សំណួរទេ។ គេអាចចាប់សំណួរនោះឆ្លើយបាន លុះត្រាតែសំណួរនៅពីលើសំណួរនោះ ត្រូវបានឆ្លើយត្រឹមត្រូវរួចហើយ។
- សិស្សក្នុងក្រុមនីមួយៗត្រូវមានចម្រុះសមត្ថភាព និងភេទដើម្បីជានាយុត្តិធម៌ក្នុងការប្រឡងប្រណាំង និងយេនឌ័រក្នុងការធ្វើការងារ
- ឱ្យសិស្សបញ្ជាក់ពីហេតុផលគ្រប់ចម្លើយ (ទាំងចម្លើយត្រឹមត្រូវ និងចម្លើយមិនត្រឹមត្រូវ)

- ចំពោះសំណួរដែលសិស្សមិនអាចឆ្លើយបាន គ្រូត្រូវគិតពិចារណាឡើងវិញពី៖ ប្រភេទសំណួរកម្រិតសំណួរ ឃ្លាប្រយោគ សមត្ថភាពសិស្ស និងគំនិតភាន់ច្រឡំ។

**ឧទាហរណ៍ដកស្រង់ពីសៀវភៅសិក្សាគោលបឋមសិក្សា (ថ្នាក់ទី4)**

មេរៀន៖ ប្រភាគ

មេរៀន៖ វិធីបូក ដកចំនួនទសភាគ

| ល.រ | ពិន្ទុ | ប្រៀបធៀប និងរៀបលំដាប់ប្រភាគ | បូក និងដកប្រភាគ | បូកចំនួនទសភាគ | ដកចំនួនទសភាគ |
|---|---|---|---|---|---|
| 1 | 5 | ប្រអប់សំណួរ | ប្រអប់សំណួរ | ប្រអប់សំណួរ | ប្រអប់សំណួរ |
| 2 | 10 | ប្រអប់សំណួរ | ប្រអប់សំណួរ | ប្រអប់សំណួរ | ប្រអប់សំណួរ |
| 3 | 15 | ប្រអប់សំណួរ | ប្រអប់សំណួរ | ប្រអប់សំណួរ | ប្រអប់សំណួរ |
| 4 | 20 | ប្រអប់សំណួរ | ប្រអប់សំណួរ | ប្រអប់សំណួរ | ប្រអប់សំណួរ |

ចំណាំ៖ គេអាចរៀបចំតារាងជេអូផាឌីនេះក្នុងស្លាយ PowerPoint បាន។

**ឧទាហរណ៍**

ប្រៀបធៀប និងរៀបលំដាប់ប្រភាគ

<u>សំណួរទទួលបាន5ពិន្ទុ</u>

- ចូរប្រៀបធៀបប្រភាគ $\frac{4}{8} \square \frac{6}{8}$ ដោយជ្រើសរើសសញ្ញាតែមួយគត់(< , = ឬ >) ដាក់ក្នុងប្រអប់ឱ្យបានត្រឹមត្រូវ (សរសេរចម្លើយលើក្ដារឆ្នួន)

<u>សំណួរទទួលបាន10ពិន្ទុ</u>

- ចូររៀបលំដាប់ប្រភាគពីតូចទៅធំ $\frac{3}{4};\frac{1}{4};\frac{2}{4};\frac{4}{4}$ (សរសេរចម្លើយលើក្ដារឆ្នួន)

<u>សំណួរទទួលបាន15ពិន្ទុ</u>

ចំណោទ៖ ម្ដាយចែកប្រាក់មួយចំនួនឱ្យកូនបីនាក់។ កូនទី១ ទទួលបាន $\frac{1}{6}$ កូនទី២ ទទួលបាន $\frac{2}{6}$ និងកូនទី3ទទួលបាន $\frac{3}{6}$ នៃប្រាក់ដែលគាត់បានចែកឱ្យ។ តើកូនទីប៉ុន្មានទទួលបានប្រាក់ច្រើនជាងគេ ? (សរសេរចម្លើយលើក្ដារឆ្នួន ឬឆ្លើយ)

<u>សំណួរទទួលបាន20ពិន្ទុ</u>

- ចូររៀបលំដាប់ចំនួនពីធំទៅតូច $\frac{5}{7};\frac{1}{7};\frac{6}{7};\frac{3}{7};1$ (សរសេរចម្លើយលើក្ដារឆ្នួន)

***វិធីបូក និងដកប្រភាគ***

<u>សំណួរទទួលបាន5ពិន្ទុ</u>

- គណនា $\frac{5}{9}+\frac{3}{9}$ (សរសេរចម្លើយលើក្ដារឆ្នួន)

<u>សំណួរទទួលបាន១០ពិន្ទុ</u>

- គណនា$1-\frac{1}{6}$ (សរសេរចម្លើយលើក្ដារឆ្នួន)

<u>សំណួរទទួលបាន15ពិន្ទុ</u>

ធីតាបានចំណាយប្រាក់សម្រាប់ទិញសៀវភៅសរសេរអស់ $\frac{1}{2}$ និងសម្រាប់ទិញប៊ិកអស់ $\frac{2}{8}$ នៃប្រាក់ទាំងអស់របស់នាង។ តើធីតាចំណាយប្រាក់អស់ប៉ុន្មានភាគនៃប្រាក់របស់នាង?

<u>សំណួរទទួលបាន20ពិន្ទុ</u>

- គ្រូមានឃ្លី៩គ្រាប់។ គាត់ចែកឱ្យសំ៣គ្រាប់ និងសុខា២គ្រាប់។ ចូរសរសេរចំនួនឃ្លីដែលនៅសល់ ជាប្រភាគធៀបទៅនឹងឃ្លីទាំងអស់?

***វិធីបូកចំនួនទសភាគ***

<u>សំណួរទទួលបាន5ពិន្ទុ</u>

- ចូរបំពេញលេខក្នុងប្រអប់ $1.5+0.3=\square$

<u>សំណួរទទួលបាន10ពិន្ទុ</u>

- ចូរបំពេញលេខក្នុងប្រអប់ $39.3+20.5=\square$

<u>សំណួរទទួលបាន15ពិន្ទុ</u>

- ចូរបំពេញលេខក្នុងប្រអប់ $\square+5.7=7.9$

<u>សំណួរទទួលបាន20ពិន្ទុ</u>

- ចូរបំពេញលេខនៅក្នុងប្រអប់ □ នៃប្រមាណវិធីបូកខាងក្រោមឱ្យបានត្រឹមត្រូវតាមផលបូក៖

```
    6  □ . 7
+
       7 . □
-----------
 7  6    . 7
```

***វិធីដកចំនួនទសភាគ***

<u>សំណួរទទួលបាន5ពិន្ទុ</u>

- ចូរបំពេញលេខក្នុងប្រអប់ $1.7-0.7=\square$

<u>សំណួរទទួលបាន10ពិន្ទុ</u>

- ចូរបំពេញលេខក្នុងប្រអប់ $1567.7-567.7=\square$

<u>សំណួរទទួលបាន15ពិន្ទុ</u>

- ចូរបំពេញលេខក្នុងប្រអប់ $9.5-\square=4.4$

<u>សំណួរទទួលបាន20ពិន្ទុ</u>

- ចំណោទ៖ ពូម៉ៅធ្វើស្ករត្នោតថ្ងៃដំបូងបាន 12.5 kg ថ្ងៃបន្ទាប់បាន15.75kg។ តើពូម៉ៅធ្វើស្ករត្នោត នៅថ្ងៃដំបូងតិចជាងថ្ងៃបន្ទាប់ប៉ុន្មានគីឡូក្រាម? (ប្រើក្ការឆ្នូន)

**សម្គាល់**

- បន្ទាប់ពីក្រុមនីមួយៗឆ្លើយសំណួរបានត្រឹមត្រូវ គ្រូឱ្យសិស្សបញ្ជាក់នូវអំណះអំណាង៖
  - ហេតុអ្វីបានជាប្អូនឆ្លើយបែបនេះ?
  - ចូរបកស្រាយពីរបៀបដោះស្រាយ។

## ៤.៧ ល្បែងផាហ្សល (Puzzle)

**សេចក្តីផ្តើម**

ល្បែងសិក្សានេះមានចម្លើយដើម្បីឱ្យសិស្សធ្វើការវាយតម្លៃខ្លួនឯង ហើយជួយពួកគេឱ្យចេះត្រួតពិនិត្យផ្ទះបញ្ជាំងលើកិច្ចការ និងធ្វើការផ្លាស់ប្តូរចម្លើយរបស់ខ្លួន។ ខ្លឹមសារល្បែងដកស្រង់ចេញពីសៀវភៅសិក្សាគោលបឋមសិក្សាថ្នាក់ទី3 ទី4 និងទី5 ។ ល្បែងសិក្សានេះលេងបានគ្រប់កម្រិតថ្នាក់ ដោយគ្រាន់តែដូរខ្លឹមសារប៉ុណ្ណោះ។

**វត្ថុបំណង**

- សិស្សបង្ហាញពីការប្រៀបធៀប បូក ដក គុណ និង ចែកប្រភាគ បានត្រឹមត្រូវ (អាចអនុវត្តបានគ្រប់ មេរៀនដូរតែខ្លឹមសារ ) ។

**សម្ភារៈជំនួយ**

- ក្រដាសកាតុងរឹង កន្ត្រៃ បន្ទាត់ ហ្វឺត ....

**របៀបផលិត**

- គូសរូបត្រីកោណសម័ង្សនៅលើក្រដាសកាតុងរឹងដូចខាងក្រោម៖
  (អាចតិច ឬច្រើនជាងនេះ)



- សរសេរប្រធានលំហាត់ និងចម្លើយចូលក្នុងត្រីកោណតូចៗនីមួយៗ
- សរសេរប្រធានលំហាត់ និងចម្លើយត្រូវគ្នានៅតាមជ្រុងរួមរបស់ត្រីកោណសម័ង្សដូចរូបខាងក្រោម។

**ឧទាហរណ៍ដកស្រង់ពីសៀវភៅសិក្សាគោលបឋមសិក្សា (ថ្នាក់ទី5)**

**មេរៀន៖ ប្រភាគ**



- នៅខាងខ្នងត្រីកោណធំ សរសេរអក្សរត្រូវគ្នានៅតាមជ្រុងរួមរបស់ត្រីកោណតូចៗ ដែលមានចម្លើយត្រូវជាមួយនឹងលំហាត់ដូចឧទាហរណ៍ខាងក្រោម៖




* សម្គាល់៖ ដើម្បីចៀសវាងការលួចមើលផ្នែកខាងក្រោយមុនរៀបចម្លើយ គ្រូអាចគូររូបអ្វីមួយនៅខាងក្រោយជំនួសឱ្យការដាក់អក្សរក៏បាន ។

គ្រូកាត់រូបត្រីកោណខាងលើឱ្យទៅជាត្រីកោណតូចៗ ដូចខាងក្រោម៖



## របៀបលេង

- ចែកសិស្សជាក្រុម ក្នុងមួយក្រុមមានគ្នាពី3ទៅ5នាក់
- គ្រូចែកត្រីកោណតូចៗដែលបានកាត់ពីត្រីកោណធំឱ្យក្រុមនីមួយៗ
- ឱ្យសិស្សច្របល់ត្រីកោណតូចៗឱ្យនៅខុសទីតាំងគ្នា
- ឱ្យសិស្សតាមក្រុមរៀបត្រីកោណតូចៗទាំងនេះឱ្យបានជាត្រីកោណធំមួយដោយធ្វើយ៉ាងណាឱ្យជ្រុងរួមរបស់ត្រីកោណតូចៗនីមួយៗឱ្យមានលំហាត់ និងចម្លើយត្រូវគ្នា
- ឱ្យសិស្សតាមក្រុមផ្តុំត្រីកោណតូចៗនេះនៅលើក្រដាសក្រាស់រឹងឬលើសៀវភៅបន្ទាប់មកយកក្រដាសរឹង ឬសៀវភៅមួយផ្សេងទៀតផ្កាប់ពីលើត្រីកោណដែលរៀបរួច
- ឱ្យសិស្សផ្ងារក្រដាសរឹង ឬសៀវភៅខាងក្រោមមកខាងលើវិញ
- សិស្សផ្ទៀងផ្ទាត់ចម្លើយ (បើផ្នែកខាងក្រោយរបស់ត្រីកោណជ្រុងរួមមានអក្សរត្រូវគ្នា ដូចជា

A និង A ដូចគ្នា B និង B ដូចគ្នាជាចម្លើយត្រូវ ប្រសិនបើមានអក្សរខុសគ្នាជាចម្លើយខុស)

- ឱ្យក្រុមសិស្សដែលធ្វើខុសរៀបឡើងវិញ
- គ្រូសួរទាំងក្រុមរៀបត្រូវ និងក្រុមរៀបខុសដែលទាក់ទងទៅនឹងវិធីរៀបរបស់គេ តើប្អូនៗមានវិធីបែបណាដើម្បីរៀបត្រីកោណតូចៗទាំងនេះឱ្យបានចម្លើយត្រឹមត្រូវ ?
- ឱ្យតំណាងក្រុមឡើងរាយការណ៍

## ជំពូក៥ ៖ ការជួយសិស្ស

បន្ទាប់ពីបានវាយតម្លៃការយល់ដឹងរបស់សិស្សរួចហើយ ដំណាក់កាលដែលត្រូវយកចិត្តទុកដាក់បំផុត គឺការដោះស្រាយនូវគំនិតភាន់ច្រឡំរបស់សិស្សនិងការជួយសិស្សរៀនយឺត។ វិធីជួយសិស្សនឹងត្រូវបង្ហាញនៅក្នុងជំពូកនេះ។



### ៥.១ ការប្រមូល និងវិភាគទិន្នន័យ

ក្នុងពេលកំពុងសិក្សាគ្រូបានត្រួតពិនិត្យតាមដានសកម្មភាពរបស់សិស្ស។ ចំណុចនេះមានសារសំខាន់ណាស់ដែលគ្រូត្រូវធ្វើការកត់សម្គាល់នៅពេលសង្កេតសិស្សទាំងនោះ។

ឧទាហរណ៍៖ នៅពេលដែលសិស្សម្នាក់មានកំហុសដដែលៗ នោះបង្ហាញថាគេមិនយល់ពីចំណុចនេះបានទេ។ តាមរយៈការកត់ត្រា គ្រូកំណត់បាននូវរចនាសម្ព័ន្ធបញ្ហា បន្ទាប់មកផ្តល់នូវព័ត៌មានត្រឡប់ដើម្បីជួយសិស្សបានទាន់ពេលវេលាយ៉ាងមានប្រសិទ្ធភាព។

កំណត់ត្រាក្រៅផ្លូវការជួយឱ្យគ្រូផ្តល់នូវការគាំទ្រសិស្សបានពេញលេញ ប៉ុន្តែជួនកាលគ្រូអាចជ្រើសរើសយកការកត់ត្រានេះសម្រាប់ធ្វើការវិនិច្ឆ័យជាផ្លូវការបន្ថែមទៀត។ ការវិភាគកំហុសអាចផ្តល់នូវព័ត៌មានលម្អិតបន្ថែមទៀតអំពីប្រភេទនៃកំហុសរបស់សិស្សដែលបានធ្វើ និងអាចផ្តល់ជាមធ្យោបាយដើម្បីជួយសិស្ស។

## តារាងវិភាគកំហុស

វិភាគកំហុស

| សិស្ស / ខ្លឹមសារលំហាត់ | ក | ខ | គ | ឃ | ង | ច | ឆ | ជ | ឈ | ញ | ដ | ប | ឌ | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 1 | | | | | | | | | | | | | | 0 |
| 2 | | | | | | | | | | | | | | 0 |
| 3 | | | | | | | | | | | | | | 0 |
| 4 | X | | | | | | | | | | | | | 1 |
| 5 | | | | | | | | | | | | | | 0 |
| 6 | X | | | | | | | | | | | | | 1 |
| 7 | X | | X | X | | | | | | | | | | 3 |
| 8 | X | | | | X | | | | | | | | | 2 |
| 9 | X | | X | | | X | | | | | X | | X | 5 |
| 10 | X | X | X | X | | | | | | | X | | | 5 |
| 11 | X | X | | | | X | | | | | | | | 3 |
| 12 | | X | | | X | | X | | | | | | | 3 |
| 13 | X | X | | X | X | | | | | X | | X | | 6 |
| 14 | X | X | | | | X | | | | | | | X | 4 |
| 15 | X | X | | | | | | | | | | | | 2 |
| 16 | X | X | | X | | | | | X | | | | | 4 |
| 17 | X | X | X | | | | | | X | X | | | | 5 |
| 18 | | X | X | | | X | | | X | | | | | 4 |
| 19 | X | X | X | | X | | | | | X | X | | | 6 |
| 20 | X | X | | X | X | X | | X | X | | X | X | X | 10 |
| សរុប | 14 | 11 | 6 | 5 | 5 | 5 | 1 | 1 | 4 | 3 | 4 | 2 | 3 | |

*សម្គាល់៖ គេអាចកែប្រែតារាងនេះឱ្យត្រូវតាមស្ថានភាពជាក់ស្តែងបានដោយដាក់ឈ្មោះសិស្សតាមជួរដេក និងលំហាត់តាមជួរឈរ។

ឧទាហរណ៍៖
តាមរយៈតារាងវិភាគកំហុសខាងលើ គ្រូអាចជួយសិស្សបានពេញលេញ និងសន្និដ្ឋានដូចខាងក្រោម៖

- សិស្ស ក និង ខ មិនសម្រេចបានតាមវត្ថុបំណងមេរៀន។ សិស្សទាំងពីរនាក់នេះ ត្រូវការនូវការជួយរៀងៗខ្លួនពីគ្រូ។
- មានលំហាត់ចំនួន 6 ដែលសិស្សយ៉ាងតិច 5 នាក់ធ្លាក់។ លំហាត់ទាំងនេះត្រូវតែពន្យល់ ទៅកាន់សិស្សទាំងអស់។
- គ្រូកត់សម្គាល់ថា សិស្សនៅមានបញ្ហាច្រើនចំពោះខ្លឹមសារលំហាត់ទី 9, 10, 13, 17, 19 និង 20។ ដូចនេះ គ្រូសម្រេចចិត្តផ្តោតសំខាន់លើលំហាត់ទាំងនេះមុននឹងបង្រៀនមេរៀនបន្ទាប់។

## ៥.២ ព័ត៌មានត្រឡប់

អាស្រ័យលើការសង្កេត គ្រូអាចផ្តល់ព័ត៌មានត្រឡប់ សិស្សដឹងពីកំហុសរបស់ខ្លួនឯង និងធ្វើការសម្រេចចិត្តបានត្រឹមត្រូវ។ មធ្យោបាយនេះជួយជំរុញការសិក្សារបស់សិស្ស។

គ្រូអាចផ្តល់ព័ត៌មានត្រឡប់ក្នុងកាលៈទេសៈខុសៗគ្នាដូចជា៖

- ពេលធ្វើលំហាត់រៀងៗខ្លួន
- ពេលធ្វើលំហាត់ជាក្រុម
- ពេលកែកិច្ចការផ្ទះ
- ពេលចែកកិច្ចការ ឬ តេស្តឱ្យសិស្សវិញ
- ពេលឱ្យសិស្សឆ្លើយសំណួរ
- ...

ព័ត៌មានត្រឡប់ដែលមានប្រសិទ្ធភាពត្រូវតែ៖

- ជាក់លាក់បើអាចទៅរួច
- បានផ្តល់ឱ្យយ៉ាងរហ័សបើអាចទៅរួច
- មានទំនាក់ទំនងគ្នាជាមួយនឹងវត្ថុបំណងមេរៀន
- បានផ្តល់ឱ្យយ៉ាងប្រុងប្រយ័ត្ន
- ជំរុញសិស្សឱ្យគិត (មិនត្រូវគ្រាន់តែផ្តល់ចម្លើយឱ្យសិស្សទេ)

## ៥.៣ ការញែកភាពខុសគ្នា

សិស្សមានឧបនិស្ស័យ និងកម្រិតបញ្ញាខុសៗគ្នា។ ពួកគេមានលក្ខណៈខុសគ្នាជាច្រើនដូចជាភាពរហ័សរហួន កម្រិតសមត្ថភាពបម្រុងប្រយ័ត្ន ការចាប់អារម្មណ៍ ។ នៅសាលារៀន សិស្សខ្លះមានការលំបាកលើខ្លឹមសារគណិតវិទ្យា ឬ អក្ខរាវិរុទ្ធ...។ ភាពលំបាករបស់សិស្សម្នាក់ៗមានកម្រិត និងតម្រូវការផ្សេងៗគ្នា សិស្សខ្លះត្រូវការជំនួយពីគ្រូឱ្យបានច្រើន សិស្សខ្លះទៀតត្រូវការពេលវេលាច្រើន សិស្សខ្លះទៀតត្រូវការសម្ភារៈជំនួយ ឯ

សិស្សខ្លះទៀតរៀនត្រូវការល្បែងសិក្សាជាដើម។ ដើម្បីជួយសិស្សទាំងនេះឱ្យមានប្រសិទ្ធភាព ទាមទារឱ្យគ្រូមានសមត្ថភាពចំណេះដឹង និងគរុកោសល្យគ្រប់គ្រាន់។ គ្រូត្រូវតែសម្របសម្រួលមេរៀនទៅតាមតម្រូវការរបស់សិស្សទាំងនេះ ដើម្បីជួយពួកគេឱ្យបានពេញលេញ។ គ្រូត្រូវធ្វើការត្រិះរិះពីភាពខុសគ្នារបស់សិស្សម្នាក់ៗ ហើយត្រូវកំណត់ និងកែលម្អយុទ្ធសាស្ត្រនៃការបង្រៀនរបស់ខ្លួនដើម្បីឆ្លើយតបទៅនឹងតម្រូវការដោយឡែកៗរបស់ពួកគេ។ តាមមធ្យោបាយនេះសិស្សទទួលបានជំនួយដែលពួកគេត្រូវការដើម្បីសម្រេចបាននូវវត្ថុបំណងមេរៀន។

ដំណាក់កាលអនុវត្តគ្រូត្រូវញែកភាពខុសគ្នារបស់សិស្សម្នាក់ៗ ដើម្បីឆ្លើយតបឱ្យត្រូវនឹងតម្រូវការរបស់ពួកគេ ជាពិសេសសិស្សរៀនយឺត។ ខណៈពេលដែលសិស្សពូកែអាចបន្តធ្វើលំហាត់ពិបាកៗបន្ថែម សិស្សមធ្យមអាចអនុវត្តបន្ថែមលើអ្វីដែលពួកគេបានរៀន និងពង្រឹងពុទ្ធិនេះ ហើយសិស្សរៀនយឺតអាចធ្វើការងារជាមួយគ្រូ និងទទួលការណែនាំបន្ថែម។

ការញែកភាពខុសគ្នាមានពីរប្រភេទ៖

1. អាស្រ័យលើល្បឿននៃការគិត
2. អាស្រ័យលើការយល់ដឹង

ក្នុងករណីការញែកភាពខុសគ្នាប្រភេទទី1 គ្រូត្រូវឱ្យកិច្ចការក្នុងចំនួនផ្សេងៗដល់សិស្ស។ សិស្សដែលធ្វើរួចមុនគេនឹងទទួលបានកិច្ចការបន្ថែមទៀត។ ក្នុងករណីការញែកភាពខុសគ្នាប្រភេទទី2 គ្រូត្រូវត្រួតពិនិត្យលើការវិភាគ កំហុសដើម្បីកំណត់ថាតើសិស្ស ណាត្រូវការជួយបន្ថែម ហើយត្រូវដាក់លំហាត់ប្រភេទណាឱ្យធ្វើបន្ថែមទៀត។

ក្នុងករណីខ្លះ គ្រូអាចថយមួយជំហានវិញក្នុងបន្ទាត់សិក្សា(learning line) សម្រាប់សិស្សរៀនយឺត ខណៈពេលដែលសិស្សផ្សេងទៀតបន្តធ្វើកិច្ចការរបស់ពួកគេធម្មតា។ សម្រាប់សិស្សរៀនយឺត គ្រូត្រូវសម្រេចចិត្តអនុវត្តលំនាំនៃការបង្រៀន ផ្តើមចេញពី រូបី គំនូសបំព្រួញ និងអរូបី ។ គ្រូអាចឱ្យសម្ភារឧបទេសបន្ថែមទៀតទៅសិស្សដើម្បីពង្រឹងការយល់ដឹងរបស់ពួកគេ។ ប៉ុន្តែគ្រូត្រូវតែជួយសិស្សក្នុងការប្រើប្រាស់សម្ភារឧបទេសទាំងនេះដោយសួរសំណួរបំផុសឱ្យសិស្សគិតដូចជា៖ តើប្អូនដោះស្រាយលំហាត់តាមវិធីណា? ហេតុអ្វីបានជាប្អូន ជ្រើសរើសមធ្យោបាយនេះ? យើងគួរតែព្យាយាមមិនឱ្យសិស្សជាប់គាំងក្នុងដំណាក់កាលណាមួយទេ។

**ឧទាហរណ៍ដកស្រង់ពីកម្មវិធីសិក្សាបឋមសិក្សា**

ឧទាហរណ៍៖ សិស្សបូកប្រភាគ $\frac{2}{3}+\frac{1}{6}$។ ក្នុងករណីនេះ អ្នកអាចឱ្យសិស្សប្រើផ្ទាំងប្រភាគ ដែលអាចធ្វើឱ្យពួកគេងាយស្រួលឈានទៅកាន់ដំណាក់កាលអរូបីមួយ។ គ្រូត្រូវឱ្យសិស្សបកស្រាយអ្វីដែល ពួកគេកំពុងតែធ្វើ និងបង្កើតឡើង។ នេះជាជំហានចាំបាច់មួយដើម្បីសម្រេចបាននូវដំណើរនេះ។ គ្រូត្រូវសួរសិស្សអំពីរបៀបដែល ពួកគេនឹងដោះស្រាយលំហាត់។ បន្ទាប់មកសិស្សត្រូវពន្យល់ថា ពួកគេមិនអាចបូក $\frac{2}{3}$ និង $\frac{1}{6}$ ផ្ទាល់បានទេជា ដំបូងពួកគេត្រូវរកភាគបែងរួមជាមុនសិន ដោយមើលលើតារាងប្រភាគ ពួកគេអាចឃើញថាភាគបែងរួមគឺ៦។ បន្ទាប់មកគ្រូអាចសួរអំពីរបៀបដែលសិស្សអាចដឹងពីភាគបែងនេះដោយមិនមើលលើផ្ទាំងប្រភាគ។ ធ្វើរបៀបនេះគឺដើម្បីជំរុញសិស្សឱ្យគិតផង និងជាស្ពានជួយតភ្ជាប់រវាងរូបី និងអរូបី ដោយផ្តល់នូវការគាំទ្រតាមគំហើញជាក់ស្តែង (ផ្ទាំងប្រភាគ ការបត់ក្រដាស...) សិស្សនឹងយល់ពីមូលហេតុនៃការតម្រូវភាគបែង។ រួចឱ្យសិស្សប្រាប់ពីអ្វីដែលពួកគេកំពុងធ្វើដោយខ្លួនគេ វានឹងមានភាពងាយស្រួលធ្វើកិច្ចការនេះម្តងទៀតដោយមិនបាច់មានការគាំទ្រតាមគំហើញជាក់ស្តែងនៅពេលក្រោយ។

# ឧបសម្ព័ន្ធ





# ឯកសារយោង

Allen, B., & Johnston-Wilder, S. (2004). *Mathematics education. Exploring the culture of learning.* New York: Digital Printing.

CIMT. (2012). Enhancing primary mathematics teaching and learning. Retrieved from http://www.cimt.plymouth.ac.uk/papers/epmtl.pdf

Hattie & Timperley (2007). *The power of feedback.* USA: SAGE.

MOEYS (2011). *Mathematics. Improve knowledge and teaching methodologies for primary schools. Part 1: numbers, calculation, measurement. Pupil activity.* Cambodia.

MOEYS (2011). *Mathematics. Improve knowledge and teaching methodologies for primary schools. Part 1: numbers, calculation, measurement. Knowledge concept and skills. Trainee version*. Cambodia.

MOEYS (2011). *Mathematics. Improve knowledge and teaching methodologies for primary schools. Part 2: algebra, statistics, geometry. Pupil activity.* Cambodia.

MOEYS (2011). *Mathematics. Improve knowledge and teaching methodologies for primary schools. Part 2: algebra, statistics, geometry. Knowledge concept and skills. Trainer version.* Cambodia.

MOEYS (2011). *Mathematics. Improve knowledge and teaching methodologies for primary schools. Part 1: numbers, calculation, measurement. How children learn. Trainer version.* Cambodia.

MOEYS (2011). *Mathematics. Improve knowledge and teaching methodologies for primary schools. Part 1: numbers, calculation, measurement. How children learn. Trainee version.* Cambodia.

MOEYS (2011). *Mathematics. Improve knowledge and teaching methodologies for primary schools. Part 2: algebra, statistics, geometry. How children learn. Trainer version.* Cambodia.

MOEYS (2011). *Mathematics. Improve knowledge and teaching methodologies for primary schools. Part 2: algebra, statistics, geometry. How children learn. Trainee version.* Cambodia.

MOEYS (2011). *Mathematics. Improve knowledge and teaching methodologies for primary schools. Part 2: algebra, statistics, geometry. Knowledge concept and skills. Trainee version.* Cambodia.

Mooney, C., Briggs, M., & Fletcher, M. (2009). *Primary mathematics. Teaching Theory and Practice (4th edition).* UK: Learning Matters.

Ontario Ministry of Education. (2005). Communication in the Mathematics Classroom. Retrieved from http://www.edu.gov.on.ca/eng/literacynumeracy/inspire/research/CBS_Communication_Mathematics.pdf

VVOB (2007). *Learner-centered methodology. Training manual for pre-service and in-service training of primary school teachers.* Cambodia.

Wright, R.J., Ellemor-Collins, D., Tabor, P.D. (2012). *Developing number knowledge. Assessment, Teaching & Intervention with 7-11-Year-Olds.* London: SAGE.

vvob
education for development

With the support of
THE BELGIAN
DEVELOPMENT COOPERATION
.be

With the support of
the governmernt of Flanders